សម្ព័ន្ធខ្មែរជំរឿន និងការពារសិទ្ធិមនុស្ស លីកាដូ
LICADHO
CAMBODIAN LEAGUE FOR THE PROMOTION AND DEFENSE OF HUMAN RIGHTS
ផ្ទះលេខ ១៦ ផ្លូវលេខ ៩៩ ប្រអប់សំបុត្រ ៤៩៩ រាជធានីភ្នំពេញ កម្ពុជា
ទូរស័ព្ទ: (+៨៥៥) ២៣ ៧២៧ ១០២/២១៦ ៦០២ ទូរសារ: (+៨៥៥) ២៣ ៧២៧ ១០២/២១៧ ៦២៦ អ៊ីមែល: contact@licadho-cambodia.org

# ឯកសារសង្ខេបស្តីពីអំពើហិង្សានៅទីលានប្រជាធិបតេយ្យ ការចាប់ខ្លួន តំណាងរាស្រ្ត ជាប់ឆ្នោតគណបក្សសង្គ្រោះជាតិ និងការចរចានយោបាយ

ដំណើរហេតុពីថ្ងៃទី១៤ ខែកក្កដា ដល់ ថ្ងៃទី២៧ ខែសីហា ឆ្នាំ២០១៤




*អំពើហិង្សាថ្មីនេះ ដែលបានកើតឡើងនៅក្បែរទីលានប្រជាធិបតេយ្យ កាលពីថ្ងៃទី១៥ ខែកក្កដា ឆ្នាំ ២០១៤ បានបង្កឲ្យមានព្រឹត្តិការណ៍ជាបន្តបន្ទាប់ជាច្រើន។ ការចាប់ខ្លួនមន្ត្រីជាគណបក្សសង្គ្រោះជាតិជាច្រើន រួមទាំងតំណាងរាស្រ្តជាប់ឆ្នោត ហើយនិងការចចារនយោបាយ បានផ្តល់នូវភស្តុតាងយ៉ាងច្បាស់ថា ប្រព័ន្ធយុត្តាធិការ គឺស្ថិតក្នុងកណ្តាប់ដៃរបស់គណបក្សកាន់អំណាច ដែលបណ្តាលឲ្យកើតមានការព្រួយបារម្ភយ៉ាងខ្លាំងអំពីភាពស្របច្បាប់ និងឯករាជ្យនៃប្រព័ន្ធច្បាប់កម្ពុជា។*

*លើសពីនេះ ការផ្អាកការសាកសួររបស់ចៅក្រមស៊ើបសួរ លោក កែវ មុនី កាលពីថ្ងៃទី២២ ខែកក្កដា នៅពេលការចរចានយោបាយរវាងគណបក្សប្រជាជនកម្ពុជា និងគណបក្សសង្គ្រោះជាតិ កំពុងប្រព្រឹត្តិទៅ គឺជាភស្តុតាងយ៉ាងច្បាស់មួយ ដែលមន្ត្រីគណបក្សសង្គ្រោះជាតិមួយចំនួនដែលត្រូវបានឃុំខ្លួន ត្រូវបានប្រើប្រាស់ក្នុងការតថ្លៃ ដោយផ្តល់នូវអាទិភាពដល់គណបក្សប្រជាជនក្នុងការនិយាយលើតុចរចានយោបាយ។*

*នៅព្រឹត្តិការណ៍ជាច្រើនក្រោយពេលចាប់ខ្លួនមន្ត្រីគណបក្សសង្គ្រោះជាតិ បណ្តាលឲ្យគណបក្សសង្គ្រោះជាតិបោះបង់យ៉ាងច្បាស់នូវការទាមទារសំខាន់ៗមួយចំនួនដែលបានដាក់ចេញនៅពេលមានភាពជាប់គាំងនយោបាយកាលពីឆ្នាំមុន។ ការចាប់ខ្លួននានាក្នុងខែតុលា និងវិច្ឆិកា ឆ្នាំ២០១៤ បានកើតឡើងនៅពេលដែលក្រុមការងារគណបក្សប្រជាជនកម្ពុជា និងគណបក្សសង្គ្រោះជាតិ កំពុងព្រាងនូវច្បាប់ស្តីពីការរៀបចំ និងប្រព្រឹត្តិទៅនៃគណកម្មាធិកាជាតិរៀបចំការបោះឆ្នោត ដែលបានជាប់គាំងដោយសារចំនុចជាច្រើន ដែល*

*រួមមានការទាមទាររបស់គណបក្សប្រជាជនកម្ពុជា ដោយសមាជិកគណកម្មការនានាត្រូវមានសញ្ជាតិខ្មែរតែមួយ។*

*ជាសរុបមក តារាងព្រឹត្តិការណ៍បន្តបន្ទាប់នេះ បានបង្ហាញនូវភស្តុតាងយ៉ាងច្បាស់ថា ការមិនមានដំណើរការ និងការធានាច្បាស់លាស់ណាមួយសម្រាប់កំណែទម្រង់នៅក្នុងការចរចានយោបាយ គឺជាលទ្ធផលដោយផ្ទាល់នៃការចាប់ខ្លួន ឃុំខ្លួន និងកោះហៅមន្ត្រីគណបក្សសង្គ្រោះជាតិដែលមានលក្ខណៈនយោបាយ ចាប់តាំងពីថ្ងៃទី១៥ ខែកក្កដា។*

## ថ្ងៃទី១៤ ខែកក្កដា ឆ្នាំ២០១៤: ហេតុការណ៍ពេលព្រឹក

ថ្នាក់ដឹកនាំគណបក្សសង្គ្រោះជាតិ បានអំពាវនាវទៅកាន់ឯកឧត្តម ស ខេង រដ្ឋមន្ត្រីក្រសួងមហាផ្ទៃដែលមកពីគណបក្សប្រជាជនកម្ពុជា សុំឲ្យលុបចោលការហាមប្រាមចំពោះការប្រមូលផ្តុំគ្នានៅ ទីលានប្រជាធិបតេយ្យ។

ជាការឆ្លើយតបទៅនឹងសំណើររបស់គណបក្សសង្គ្រោះជាតិ អ្នកនាំពាក្យក្រសួងមហាផ្ទៃ លោក ខៀវ សុភ័ក្រ្ត បានអះអាងថា " អ្នកតំណាងរាស្រ្តគណបក្សសង្គ្រោះជាតិ មិនទាន់ជាតំណាងរាស្រ្តនៅឡើយទេ [ដូច្នេះ]នគបាលអាចវាយពួកគាត់បាន[៩]" ។

## ថ្ងៃទី១៥ ខែកក្កដា ឆ្នាំ២០១៤: ហេតុការណ៍ពេលព្រឹក

នៅម៉ោងប្រហែល ៧:៤៥ ព្រឹក ក្រុមសន្តិសុខប្រមាណ ៦០ នាក់ និងអ្នកគាំទ្រ គណបក្សសង្គ្រោះជាតិរាប់សិបនាក់ បានប្រមូលផ្តុំគ្នានៅលើស្ពាននាគ។ ទន្ទឹមគ្នានោះដែរ កងនគបាលអន្តរាគមន៍រាប់រយនាក់ បំពាក់ដោយឧបករណ៍បង្ក្រាបកុបកម្ម និងឧបករណ៍សម្រាប់បាញ់គ្រាប់បែកផ្សែង ស្ថិតនៅក្នុងបរិវេណទីលានប្រជាធិបតេយ្យដែលហ៊ុំព័ន្ធទៅ ដោយបន្លាលួស។

នៅក្រៅក្រសួងកិច្ចការនារីវិញ លោក ហូ វ៉ាន់ តំណាងរាស្រ្តជាប់ឆ្នោតរបស់គណបក្សសង្គ្រោះជាតិ ចាប់ផ្តើមថ្លែងទៅកាន់អ្នកសារព័ត៌មានប្រជាជន ដែលមានមូលដ្ឋាននៅលើបណ្តាញសង្គមហ្វេសប៊ុក។ អ្នកឃ្លាំមើលសិទ្ធិមនុស្សអង្គការលីកាដូ បានប្រទះឃើញកំណាត់ដំបងឬស្សី ក្នុងការុងនៅលើគូថឡានពណ៌សរ ដែលចតនៅចម្ងាយប្រមាណ ៥០ ម៉ែត្រ ខាងជើងស្ពាននាគ ដែលជាទីតាំងអាជ្ញាធរឈរជើង។

តំណាងរាស្រ្ត លោកស្រី មូរ សុខហួរ និង លោក ឡុង រី ក្នុងចំណោមតំណាងរាស្រ្តគណបក្សសង្គ្រោះជាតិផ្សេងទៀត បានមកដល់ជាមួយអ្នកគាំទ្រប្រមាណ ២០០ នាក់ ហើយបានចូលគ្នាជាមួយអ្នកគាំទ្រ

---

[៩] Meas, S., „Freedom Park braces for violence", Phnom Penh Post, July 15 2014
http://www.phnompenhpost.com/national/freedom-park-braces-violence

ប្រហែល ១០០ នាក់ ដែលមានវត្តមាននៅទីនោះស្រាប់។ បន្ទាប់មកអ្នកគាំទ្រទាំងនោះ បានដើរទៅកាន់របាំងលួសដែលស្ថិតនៅភាគខាងត្បូងលើស្ពាននាគ (កែងផ្លូវ ១០៨ និងមហាវិថី ព្រះនរោត្តម) ដើម្បីចងបដាដែលសរសេរថា "ដោះលែងទីលាន ប្រជាធិបតេយ្យ"។

អ្នកគាំទ្រគណបក្សសង្គ្រោះជាតិមួយក្រុម បានដើរទៅរបាំងលួសភាគខាងជើង ដែលស្ថិតនៅចុងស្ពាននាគ (កែងរវាងផ្លូវព្រះមហាក្សត្រីយានីកុសមៈ និងមហាវិថី ព្រះនរោត្តម) ជាមួយនឹងបដាពណ៌ទឹកក្រូចធំមួយ។ ស្របពេលនោះដែរ អ្នកតំណាងរាស្ត្រជាប់ឆ្នោតគណបក្សសង្គ្រោះជាតិបន្តស្ថិតនៅចុងស្ពាននាគភាគខាងត្បូង ដោយថ្លែង ទៅកាន់អ្នកគាំទ្រ និងអ្នកសារព័ត៌មាន។

ក្រុមសន្តិសុខជ្រួលច្រាល និងសាកល្បងប្រដាប់ឆក់របស់ខ្លួន នៅចុងស្ពាននាគ ភាគ ខាងជើង។ ក្រុមសន្តិសុខបានទៅទាញទំលាក់ផ្ទាំងបដាពណ៌ទឹកក្រូច ដែលចងនៅលើរបាំងលួសភាគខាងជើងនោះភ្លាមៗ បន្ទាប់ពីអ្នកគាំទ្រគណបក្សសង្គ្រោះជាតិចងរួច។

ក្រុមអ្នកគាំទ្របានទៅការពារផ្ទាំងបដាពណ៌ទឹកក្រូចនោះ។ ក្រុមសន្តិសុខ ចាប់ផ្តើមវាយក្បាលអ្នកគាំទ្រនឹងដំបង។ អ្នកគាំទ្រដែលមានកំហឹងខ្លះ តបតវិញ ដោយវាយក្រុមសន្តិសុខជាមួយនឹងបំពង់ទីបជ័រពណ៌ខៀវ (ប្រើសម្រាប់ចងទង់ជាតិ)។ ក្រុមសន្តិសុខចាប់ ផ្តើមរត់ ហើយទំលាក់ដំបងរបស់ខ្លួនចោល។ ក្រុមអ្នកគាំទ្ររើសដំបងទាំងនោះ ហើយបន្តវាយ ក្រុមសន្តិសុខ។

ពេលហេតុការណ៍នេះកើតឡើង នគរបាលអន្តរាគមន៍ (ខុសពីអ្វីដែលនគរបាលអន្តរាគមន៍ធ្លាប់ធ្វើកន្លង) មកមិនបានចេញមកការពារ និងជួយដល់ក្រុមសន្តិសុខនោះទេ។ នគរបាលភាគច្រើននៅស្ងៀមពេលដែលអំពើហិង្សាកើតឡើង។ នគរបាលពីរ ឬបីនាក់បានបាញ់គ្រាប់បែកផ្សែង។

ពេលដែលអំពើហិង្សាបានស្រាកស្រាន្ត អ្នកគាំទ្របានប្រមូលផ្តុំគ្នានៅលើស្ពាននាគម្តងទៀត នៅកន្លែងតំណាងរាស្ត្រជាប់ឆ្នោតគណបក្សសង្គ្រោះជាតិ បានរៀបចំគ្រឿងឃោសនស័ព្ទនៅលើម៉ូតូកង់បី។ តំណាងរាស្ត្រជាប់ឆ្នោតគណបក្សសង្គ្រោះជាតិ បានថ្លែងសុន្ទរកថា ដោយជម្រុញឲ្យអនុវត្តវប្បធម៌អហិង្សារួមទាំងសូមឲ្យមានការគោរពសិទ្ធិជាមូលដ្ឋានផងដែរ។

អំពើហិង្សាលើកទីពីរបានកើតឡើង ពេលក្រុមសន្តិសុខ ដែលបានឈរនៅឆ្ងាយពីក្រុមអ្នកគាំទ្រចាប់ផ្តើមដើរសំដៅមកកាន់ស្ពាននាគ។ អ្នកឃ្លាំមើលសិទ្ធិមនុស្សរបស់អង្គការ លីកាដូ លឺការអំពាវនាវរបស់តំណាងរាស្ត្រជាប់ឆ្នោតគណបក្សសង្គ្រោះជាតិ កុំឲ្យវាយក្រុមសន្តិសុខ និងឲ្យឈរនៅលើស្ពាននាគ។

បន្ទាប់ពីអំពើហិង្សាកើតឡើង តំណាងរាស្ត្រជាប់ឆ្នោតគណបក្សសង្គ្រោះជាតិ ៣ រូប លោកស្រី មូរ សុខហួរ លោក កែវ ភារម្យ និងលោក ម៉ែន សុថាវរិន្ទ្រ ត្រូវបានចាប់ខ្លួននៅស្ពាននាគ ហើយត្រូវបានបញ្ជូនទៅកាន់ប៉ុស្តិ៍នគរបាលវត្តភ្នំ ដែលស្ថិតនៅក្នុងបរិវេណទីលានប្រជាធិបតេយ្យដែលហ៊ុំព័ទ្ធទៅដោយរបងលួ

ស។ បន្ទាប់មកទៀត តំណាងរាស្ត្រជាប់ឆ្នោតទាំង ៣ នាក់ ត្រូវបានបញ្ជូនទៅកាន់ស្នងការដ្ឋាននគរបាលរាជធានីភ្នំពេញ។

**<u>ថ្ងៃទី១៥ ខែកក្កដា ឆ្នាំ២០១៤: ហេតុការណ៍ពេលរសៀល</u>**

លោក ហូ វណ្ណ ត្រូវបានកោះហៅឲ្យចូលខ្លួន ដើម្បីសាកសួរ ហើយលោកបានបង្ហាញ ខ្លួននៅស្នងការដ្ឋាននគរបាលរាជធានីភ្នំពេញ ដោយឆន្ទៈផ្ទាល់ខ្លួនរបស់លោក ហើយត្រូវបានឃាត់ខ្លួនខណៈពេលមានអ្នកគាំទ្រប្រមាណ ៣០០ នាក់ ប្រមូលផ្ដុំនៅខាងក្រៅ។

នៅល្ងាចថ្ងៃនោះ ចំនួនអ្នកគាំទ្របានកើនឡើងដល់ ប្រមាណ ៨០០ នាក់ ពីព្រោះពួកគាត់រួមសាមគ្គីគ្នា ដើម្បីទាមទារឲ្យមានការដោះលែងតំណាងរាស្ត្រជាប់ឆ្នោតដែលត្រូវបានចាប់ខ្លួន។

ស្រដៀងគ្នានឹងសវនការសកម្មជនសិទ្ធិមនុស្ស និងកម្មកររោងចក្រទាំង ២៣ នាក់ ដែរ សាលាដំបូងរាជធានីភ្នំពេញ ត្រូវបានហ៊ុំព័ទ្ធទៅដោយរបាំងជាច្រើន។ អ្នកសារព័ត៌មាន និងបុគ្គលិក អង្គការមិនមែនរដ្ឋាភិបាលខ្លះមិនត្រូវបានអនុញ្ញាតឲ្យចូលនោះទេ។ វត្តមានរបស់នគរបាលគឺមានយ៉ាងច្រើន ដោយកងរាជអាវុធហត្ថប្រហែល ៣០០ ទៅ ៤០០ នាក់ ស្ថិតនៅក្នុងបរិវេណពហុកីឡាដ្ឋានជាតិអូឡាំពិកដែលនៅក្បែរនោះ ហើយក៏មានរថពាសដែកនៅលើដងវិថី និងមន្ត្រីច្រើនជាងមុនផងដែរ។

តំណាងរាស្ត្រជាប់ឆ្នោតទាំង ៤ រូប ដែលត្រូវបានចាប់ខ្លួន គិតត្រឹមវេលានេះរួមមាន៖

- លោកស្រី មូរ សុខហួរ មណ្ឌលបាត់ដំបង
- លោក ម៉ែន សុថាវរិន្ទ្រ មណ្ឌលកំពង់ធំ
- លោក កែវ ភារម្យ មណ្ឌលក្រចេះ
- លោក ហូ វ៉ាន់ មណ្ឌលភ្នំពេញ

**<u>ថ្ងៃទី១៦ ខែកក្កដា ឆ្នាំ២០១៤: ហេតុការណ៍ពេលព្រឹក</u>**

នៅម៉ោង ២ ព្រឹក លោក រៀល ខេមរិន្ទ្រ តំណាងរាស្ត្រជាប់ឆ្នោតគណបក្សសង្គ្រោះជាតិ មណ្ឌលស្វាយរៀង ត្រូវបានចាប់ខ្លួន។

នៅម៉ោង ៩ ព្រឹក គណបក្សសង្គ្រោះជាតិរៀបចំសន្និសីទការសែត នៅទីស្នាក់ការកណ្ដាលរបស់គណបក្ស ក្រោមអធិបតេយ្យភាពឯកឧត្តម កឹម សុខា អនុប្រធានគណបក្សសង្គ្រោះជាតិ ដើម្បីឆ្លើយតបនឹងហេតុការណ៍ដែលបានកើតឡើងនៅទីលានប្រជាធិបតេយ្យ។ ឯកឧត្តម កឹម សុខា អះអាងថា អំពើហិង្សានៅទីលានប្រជាធិបតេយ្យចាប់ផ្ដើមដោយអាជ្ញាធរមុន។ ការអះអាងនេះក៏ត្រូវបានបញ្ជាក់ដោយប្រភពជាច្រើនពីសំណាក់អ្នកឃ្លាំមើលសិទ្ធិមនុស្ស និងអ្នកសារព័ត៌មានឯករាជ្យជាច្រើននាក់ទៀត។

នៅចុងបញ្ចាប់នៃសន្និសីទការសែត ឯកឧត្តម កឹម សុខា បានស្នើឲ្យតំណាងរាស្ត្រជាប់ឆ្នោតគណបក្សសង្គ្រោះជាតិទាំងអស់ដែលមានវត្តមាន អញ្ជើញទៅសាលាដំបូងរាជធានីភ្នំពេញ ជាកន្លែងដែលអ្នកទាំងនោះទាមទារឲ្យមានការដោះលែងសហសេវិករបស់ពួកគាត់។

នៅម៉ោង ១១ ព្រឹក រាជរដ្ឋាភិបាល រៀបចំសន្និសីទកាសែតមួយនៅទីស្តីការគណៈរដ្ឋមន្ត្រី ដោយលោក កែវ រ៉េមី ជាអ្នកនាំពាក្យទីស្តីការគណៈរដ្ឋមន្ត្រី និងអង្គភាពប្រតិកម្មរហ័ស អះអាងថា អំពើហិង្សានៅទីលានប្រជាធិបតេយ្យជា "សកម្មភាពអាណាធិបតេយ្យ ដែលមានការរៀបចំទុកជាមុន តាមរយៈលើទំព័រហ្វេសប៊ុករបស់លោកស្រី មូរ សុខហួរ"[២]។ ក្នុងការព្យាយាមការពារ ការអះអាងរបស់ខ្លួន លោក កែវ រ៉េមី បានដកស្រង់ការផ្សព្វផ្សាយលើបណ្ដាញសង្គមហ្វេសប៊ុករបស់គណបក្សសង្គ្រោះជាតិ ដែលជម្រុញឲ្យមនុស្សមកប្រមូលផ្ដុំ ដើម្បីទាមទារទីលានប្រជាធិបតេយ្យមកវិញ។ ទោះជាយ៉ាងក៏ដោយ ការផ្សព្វផ្សាយទាំងនេះពិតជាមិនបាន ញុះញង់ឲ្យមានអំពើហិង្សានោះទេ។

លោក កែវ សុជាតិ ជាព្រះរាជអាជ្ញាកាន់សំណុំរឿង និងលោក កែវ មុនី ចៅក្រមស៊ើបសួរករណីនេះចាប់ផ្ដើមធ្វើការសាកសួរតំណាងរាស្ត្រជាប់ឆ្នោតគណបក្សសង្គ្រោះជាតិទាំង ៥ រូប។ ក្រោយពេលសាកសួរតំណាងរាស្ត្រជាប់ឆ្នោតទាំង ៥ រូប ត្រូវបានឃុំនៅក្នុងបន្ទប់ព្រះរាជអាជ្ញា ដើម្បីរង់ចាំមើលថាតើការចោទប្រកាន់លើពួកគាត់នឹងត្រូវប្រកាសឬយ៉ាងណា។

នៅវេលាម៉ោង ១១: ១៥ ព្រឹក បន្ទាប់ពីសន្និសីទការសែតរបស់គណបក្សសង្គ្រោះជាតិ លោក អឿ ណារិទ្ធិ ដែលជាអ្នកទទួលខុសត្រូវចំពោះកិច្ចការសាធារណៈនៃនាយកដ្ឋានកិច្ចការសាធារណៈរបស់គណបក្សសង្គ្រោះជាតិ ក៏ត្រូវបានចាប់ខ្លួនផងដែរ។ រថយន្តរបស់អង្គការ លីកាដូ ដែលបានដឹកលោកទៅកាន់ទីស្នាក់កណ្ដាលគណបក្សសង្គ្រោះជាតិ ត្រូវបានព័ទ្ធដោយនគរបាល ហើយបានបង្ខំឲ្យលោកចាកចេញពីក្នុងរថយន្ត។ បើទោះជាបុគ្គលិក អង្គការ លីកាដូព្យាយាមស្នើសុំឲ្យនគរបាលទាំងនោះបង្ហាញដីកាចាប់ខ្លួនម្ដងហើយម្ដងទៀតក៏ដោយ នគរបាលបដិសេធក្នុងការបង្ហាញ ហើយដឹកលោក ណារិទ្ធិ ទៅកាន់សាលាដំបូងរាជធានីភ្នំពេញ។[៣]

## ថ្ងៃទី១៦ ខែកក្កដា ឆ្នាំ២០១៤: ហេតុការណ៍ពេលល្ងាច

នៅរសៀលថ្ងៃនោះ មានការប្រកាសថា មន្ត្រីគណបក្សសង្គ្រោះជាតិទាំងអស់នឹងត្រូវបានគេចោទប្រកាន់។ បទចោទគឺយោងតាមមាត្រា ២៨ និង២១៨ (ផ្ដើមគំនិតបង្កហិង្សាដោយចេតនាមាន ស្ថានទម្ងន់

---

[២] Kuch, N., "CNRP Officials Imprisoned on Insurrection Charges," The Cambodia Daily, July 17 2014, http://www.cambodiadaily.com/news/cnrp-officials-sent-to-prison-on-charges-of-insurrection-64320/

[៣] Kuch, N. & Mech, D., "Sixth CNRP Official Arrested Following Protest", Phnom Penh Post, July 16 2014, http://www.cambodiadaily.com/news/sixth-cnrp-official-arrested-following-violent-protest-64247/

ទោស) មាត្រា ៤៩៥ (ញុះញង់ឲ្យប្រព្រឹត្តបទឧក្រិដ្ឋ) មាត្រា ៤៥៩ (ដឹកនាំឲ្យមាន ចលនាកុបកម្ម) នៃក្រមព្រហ្មទណ្ឌ។ បទល្មើសចុងក្រោយ (មាត្រា ៤៥៩) នឹងត្រូវផ្តន្ទាទោស ឲ្យជាប់ពន្ធនាគារយ៉ាងតិច ៣០ ឆ្នាំ។ ចៅក្រមស៊ើបសួរ កែវ មុនី ចាប់ផ្តើមសាកសួរជនត្រូវ ចោទម្តងម្នាក់។ មន្ត្រីរបស់គណបក្សសង្គ្រោះជាតិទាំងអស់នោះ ត្រូវបានបញ្ជូនទៅកាន់មណ្ឌលអប់រំកែប្រែទី ១ (ម១) និងមណ្ឌលអប់រំកែប្រែទី២ (ម២) ដើម្បីទទួលការឃុំខ្លួនបណ្តោះអាសន្ន។[៤]

នៅល្ងាចថ្ងៃនោះ លោក ស ខេង រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ បានបញ្ជាឲ្យចៅហ្វាយខេត្ត-ក្រុងទាំងអស់បំបែករាល់បាតុកម្មណា ដែលអាចនាំឲ្យមានការញុះញង់ឲ្យមានអំពើហិង្សា។ ការបញ្ជានេះបានបំបិទសេរីភាពក្នុងការប្រមូលផ្តុំទាំងស្រុង ដែលជាសិទ្ធិមានចែងនៅក្នុងរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា។

បន្ទាប់ពីសកម្មភាពនៅថ្ងៃនោះ ក្រសួងយុត្តិធម៌រៀបចំកិច្ចប្រជុំជាមួយមន្ត្រីស្ថានទូត រួមទាំងតំណាងអង្គការសហប្រជាជាតិ ដើម្បីពន្យល់អំពីករណីចាប់ខ្លួនតំណាងរាស្ត្រជាប់ឆ្នោតគណបក្សសង្គ្រោះជាតិ។ ក្នុងចំណោមអគ្គរាជទូត និងរដ្ឋទូត ដែលបានចូលរួមក្នុងកិច្ចប្រជុំនោះ ប្រទេសជាច្រើនបានចោទសួរចំពោះចំណាត់ការរបស់រាជរដ្ឋាភិបាលកម្ពុជា និងប្រៀបធៀបការចាប់ខ្លួនមន្ត្រីគណបក្សសង្គ្រោះជាតិ ទៅនឹងការមិនចាត់ការស៊ើបអង្កេត ឬ ផ្តន្ទាទោស ចំពោះការសម្លាប់បាតុករ និងអ្នកឈរមើល ដែលប្រព្រឹត្តដោយកងកម្លាំងសន្តិសុខជាតិកាលពីឆ្នាំមុន។

**<u>ថ្ងៃទី១៧ ខែកក្កដា ឆ្នាំ២០១៤: ហេតុការណ៍ពេលព្រឹក</u>**

លោក កឹម សុខា ទទួលបានដីកាកោះហៅសាកសួរ នៅសាលាដំបូងរាជធានីភ្នំពេញ នាថ្ងៃ ទី២៥ ខែកក្កដា វេលាម៉ោង ៨ ព្រឹក ទាក់ទងនឹងអំពើហិង្សាដែលបានកើតឡើងកាលពីថ្ងៃទី១៥ នៅឯទីលានប្រជាធិបតេយ្យ។

**<u>ថ្ងៃទី១៧ ខែកក្កដា ឆ្នាំ២០១៤: ហេតុការណ៍ពេលល្ងាច</u>**

តំណាងរាស្ត្រជាប់ឆ្នោតគណបក្សសង្គ្រោះជាតិ ២ រូបថែមទៀត គឺលោក ឡុង រី មកពីមណ្ឌលបន្ទាយមានជ័យ និងលោក នុត រំដួល មកពីមណ្ឌលកំពង់ស្ពឺ រួមជាមួយសកម្មជនគណបក្សសង្គ្រោះជាតិ ១ រូប ផ្សេងទៀត គឺលោក ឃិន ជំរឿន មានឈ្មោះនៅក្នុងឯកសារនៅតុលាការ ត្រូវបានចោទប្រកាន់ជាផ្លូវការដោយព្រះរាជអាជ្ញាកាន់សំនុំរឿងនេះ។

---

[៤] លីកាដូ, "*ការផ្សាយព័ត៌មានផ្ទាល់៖ មួយថ្ងៃបន្ទាប់ពីហិង្សានៅទីលានប្រជាធិបតេយ្យ៖ តំណាងរាស្ត្រប្រាំនាក់បានបញ្ជូនទៅតុលាការ*", ថ្ងៃទី១៦ ខែកក្កដា ឆ្នាំ២០១៤, http://stream.licadho-cambodia.org/five_elect_cnrp_court/khmer/

នៅម៉ោងប្រហែល ៤ ល្ងាច លោក ឡុង រី និងលោក នុត រំដួល ត្រូវបានចាប់ខ្លួន នៅគេហដ្ឋានរបស់លោក ឡុង រី ខណៈពួកគាត់កំពុងរង់ចាំមេធាវីរបស់ពួកគាត់។[៥] ពួកគាត់ត្រូវ បានឃុំឃាំងនៅស្នងការនគរបាលរាជធានីភ្នំពេញនាយប់នោះ។

រហូតមកដល់ពេលបច្ចុប្បន្ននេះ តំណាងរាស្ត្រជាប់ឆ្នោតគណបក្សសង្គ្រោះជាតិ ៧ រូប និងសកម្មជនគណបក្សសង្គ្រោះជាតិ ១ រូប ត្រូវបានចាប់ខ្លួន តែក្នុងរយៈពេល ៤៨ ម៉ោង ចាប់តាំងពីព្រឹត្តិការណ៍ហិង្សាថ្ងៃទី១៥ ខែកក្កដា។

នៅល្ងាចថ្ងៃដដែលនោះ ត្រូវបានគេរាយការណ៍ថា នគរបាលកំពុងស្វែងរកចាប់ខ្លួនលោក មៀច សុវណ្ណារ៉ា តំណាងរាស្ត្រមណ្ឌលបន្ទាយមានជ័យ។[៦]

## ថ្ងៃទី១៨ ខែកក្កដា ឆ្នាំ២០១៤: ហេតុការណ៍ពេលព្រឹក

នាព្រលឹមថ្ងៃទី១៨ ខែកក្កដា តំណាងរាស្ត្រជាប់ឆ្នោតគណបក្សសង្គ្រោះជាតិ លោក ឡុង រី និងលោក នុត រំដួល ត្រូវបានបញ្ជូនទៅសាលាដំបូងរាជធានីភ្នំពេញ ហើយចៅក្រមស៊ើបសួរ លោក កែវ មុនី សាកសួរពួកគាត់។

បន្ទាប់ពីការសាកសួរ លោក កែវ មុនី បញ្ជាឲ្យឃុំខ្លួនតំណាងរាស្ត្រជាប់ឆ្នោតទាំងពីរជាបណ្តោះអាសន្ន នៅមណ្ឌលអប់រំកែប្រែទី១។ អ្នកទាំងពីរត្រូវបានបញ្ជូនទៅកាន់មណ្ឌលអប់រំកែប្រែទី១ នៅម៉ោងប្រហែល ៩:៣០ ព្រឹក ដោយត្រូវចូលរួមជាមួយមន្ត្រីគណបក្សសង្គ្រោះជាតិផ្សេងទៀត ដែលបានជាប់ឃុំឃាំងកាលពីថ្ងៃទី១៥ ១៦ និង ១៧។ សរុប មន្ត្រីគណបក្សសង្គ្រោះ ជាតិចំនួន ៨ រូប ត្រូវបានជាប់ឃុំឃាំងបណ្តោះអាសន្ន ទាក់ទងនឹងបទល្មើសពាក់ព័ន្ធ នឹងអំពើហិង្សា ដែលបានកើតឡើងនៅទីលានប្រជាធិបតេយ្យកាលពីថ្ងៃទី១៥។

បន្ទាប់ពីការចាប់ខ្លួនលោក ឡុង រី និងនុត រំដួល ឯកឧត្តម សម រង្ស៊ី ប្រធាន គណបក្សសង្គ្រោះជាតិបានសរសេរសារអេឡិចត្រូនិក មកកាន់កាសែតភ្នំពេញប៉ុស្តិ៍ ដោយ បញ្ជាក់ថា លោកនឹងវិលត្រលប់ពីអឺរ៉ុបមកប្រទេសកម្ពុជា នៅថ្ងៃទី១៩ វេលាម៉ោង ៩:០៥ ព្រឹក។[៧]

---

[៥] Naren, K., "Police Arrest Two More Opposition Officials", The Cambodia Daily, July 18 2014, http://www.cambodiadaily.com/news/police-arrest-two-more-opposition-officials-64417/

[៦] Kuch, N. & Blomberg, M., "Parties Offer Conflicting Narratives of Protest Clash", The Cambodia Daily, Jul 18 2014, http://www.cambodiadaily.com/news/parties-offer-conflicting-narratives-of-protest-clash-64509/

[៧] Post Staff, "Roundup of CNRP Continues", Phnom Penh Post, July 18 2014, http://www.phnompenhpost.com//national/roundup-cnrp-continues

## ថ្ងៃទី១៩ ខែកក្កដា ឆ្នាំ២០១៤: ហេតុការណ៍ពេលព្រឹក

នៅអាកាសយានដ្ឋានអន្តរជាតិភ្នំពេញ អ្នកគាំទ្រគណបក្សសង្គ្រោះជាតិរាប់រយនាក់ ប្រមូលផ្តុំរង់ចាំការត្រលប់មកដល់របស់ ឯកឧត្តម សម សង្ស៊ី ប្រធានគណបក្សសង្គ្រោះជាតិនៅម៉ោង ៩ ព្រឹក។ ខណៈពេលនោះនគរបាលអន្តរាគមន៍ដែលបំពាក់ដោយអាវុធមួយក្រុមតូច ដែលត្រូវបានគេដាក់ចម្ងាយ ១០០ ម៉ែត្រ មានវត្តមាននៅភាគខាងត្បូងនៃរាជធានីភ្នំពេញ ក្បែរទីស្នាក់កណ្តាលរបស់គណបក្សសង្គ្រោះជាតិ។

ចំនួនមនុស្សប្រមូលផ្តុំ នៅអាកាសយានដ្ឋាន មានចំនួនលើសពី ១០០០ នាក់ ពីព្រោះ អ្នកទាំងនោះមកពីរាជធានីភ្នំពេញផង និងតាមបណ្តាខេត្តផង។ បន្ទាប់ពីយន្តហោះចុះចត ឯកឧត្តម សម រង្ស៊ី បានអំពាវនាវឲ្យដោះលែងសហសេវិករបស់លោកជាបន្ទាន់ និងបើកទីលានប្រជាធិបតេយ្យឡើងវិញ។

តាមរយៈសុន្ទរកថារបស់ឯកឧត្តម ឯកឧត្តម សម រង្ស៊ី ប្រកាសថា ឯកឧត្តមនឹងដឹកនាំក្រុមអ្នកគាំទ្រទៅកាន់ទីលានប្រជាធិបតេយ្យ និងវត្តភ្នំ។ ចំនួនអ្នកចូលរួមកាន់តែមានការកើនឡើង ហើយ អ្នកគាំទ្ររបស់គណបក្សសង្គ្រោះជាតិ បានឈរតាមដងមហាវិថីសហព័ន្ធរុស្ស៊ី។ ត្រឹមម៉ោង ១០:៤៥ នាទីព្រឹក ក្រុមដឹកនាំនៃក្រុមអ្នកគាំទ្រមកដល់រង្វង់មូលទួលគោក។ អ្នកឃ្លាំមើលអង្គការ លីកាដូ ព្យាករណ៍ចំនួនអ្នកចូលរួមជាអតិបរមាមានចំនួន ១៥០០០ នាក់។

នៅម៉ោង ១១:១៥ ព្រឹក ឯកឧត្តម សម រង្ស៊ី មកដល់ខាងមុខទីស្តីការគណៈរដ្ឋមន្ត្រី ហើយប្រកាសថាគាត់នឹងស្វែងរកដំណោះស្រាយនយោបាយ ដើម្បីដោះលែងអ្នកតំណាងរាស្ត្រជាប់ឆ្នោតដែលត្រូវបានចាប់ខ្លួន។ ឯកឧត្តម សម រង្ស៊ី បន្ទាប់មកសម្រេចដឹកនាំក្រុមអ្នកគាំទ្រទៅកាន់ទីស្នាក់ការកណ្តាលគណបក្សសង្គ្រោះជាតិជាជាងទៅវត្តភ្នំ។

ពេលក្រុមអ្នកគាំទ្រធ្វើដំណើរឆ្ពោះទៅកាន់ទីស្នាក់ការកណ្តាលគណបក្សសង្គ្រោះជាតិ ឯកឧត្តម សម រង្ស៊ី បានថ្លែងសុន្ទរកថាទៅកាន់ក្រុមអ្នកគាំទ្រម្តងទៀត ជាមួយនឹងឯកឧត្តម កឹម សុខា និង លោក មៀច សុវណ្ណារ៉ា ជាអ្នកដែលត្រូវបានគេរាយការណ៍ថា នគរបាលកំពុងស្វែងរកចាប់ខ្លួនតាំងពីថ្ងៃ ទី១៧ ខែកក្កដាមកនោះ។

ជាការមានប្រសាសន៍ទៅកាន់ក្រុមអ្នកគាំទ្រ ឯកឧត្តម កឹម សុខា អះអាងថា គណបក្សសង្គ្រោះជាតិនឹងប្រើប្រាស់តែមធ្យោបាយអហិង្សា ដើម្បីឲ្យមានការដោះលែងតំណាងរាស្ត្រជាប់ឆ្នោតទាំងអស់របស់គណបក្ស។

## ថ្ងៃទី១៩ ខែកក្កដា ឆ្នាំ២០១៤: ហេតុការណ៍ពេលល្ងាច

នៅម៉ោង ១២: ៣០ នាទីល្ងាច ឯកឧត្តម សម រង្ស៊ី ប្រកាសថា គណបក្សសង្គ្រោះជាតិ នឹងស្នើឲ្យមានជំនួបកំពូលជាមួយមន្រ្តីគណបក្សប្រជាជន នៅថ្ងៃច័ន្ទ ទី២១ ខែកក្កដា [ជំនួប កំពូលត្រូវបានលើកទៅថ្ងៃអង្គារ ទី២២ ខែកក្កដា នៅម៉ោង ៩ព្រឹកវិញ] ដើម្បីស្វែងដំណោះស្រាយបញ្ហាទាំងអស់ ទាក់ទងនឹងកំណែទម្រង់ប្រព័ន្ធបោះឆ្នោត ការបើកទីលានប្រជាធិបតេយ្យឡើងវិញ និងការដោះលែងមន្រ្តី និងសកម្មជនគណបក្សសង្គ្រោះជាតិ។

នៅចុងថ្ងៃនោះ តុលាការខេត្តកណ្តាល បានកោះហៅ លោក ចាន់ ចាង តំណាងរាស្រ្តជាប់ឆ្នោតរបស់គណបក្សសង្គ្រោះជាតិ មណ្ឌលខេត្តកណ្តាល និងមេធាវីរបស់លោក គឺលោក ជួង ជូងី មកចូលរួមសវនការនៅថ្ងៃទី២២ ខែកក្កដា ចំពោះបទចោទទាក់ទងនឹងហេតុការណ៍ ដែលកើតឡើងតាំងពីឆ្នាំ២០១១។ តុលាការអះអាងថា លោក ចាន់ ចាង បានជួយដល់ការរត់គេចខ្លួនរបស់លោក មាស ប៉េង សកម្មជន និងអតីតសមាជិកក្រុមប្រឹក្សាឃុំរបស់គណបក្សជំទាស់ ដែលបានឃុំឃាំងដោយការចោទថា បានបំផ្លិចបំផ្លាញទ្រព្យសម្បត្តិឯកជន។[៨] មិនមានបទចោទប្រកាន់លើរូបលោកនោះទេនៅពេលនោះ។ ការបើកសវនការនេះគឺពិតជាមានហេតុផលនយោបាយ ដើម្បីដាក់សម្ពាធបន្ថែមទៀត លើគណបក្សសង្គ្រោះជាតិ មុនពេលជួបចរចារ។

## ថ្ងៃទី២០ ខែកក្កដា ឆ្នាំ២០១៤: ហេតុការណ៍ពេលព្រឹក

ក្រុមគ្រួសាររបស់មន្រ្តីគណបក្សសង្គ្រោះដែលជាប់ឃុំឃាំងបន្តទៅសួរសុខទុក្ខអ្នកទាំងនោះ នៅពន្ធនាគារព្រៃសរ ប៉ុន្តែមិនត្រូវបានគេអនុញ្ញាតឲ្យចូលជួបឡើយ។

## ថ្ងៃទី២០ ខែកក្កដា ឆ្នាំ២០១៤: ហេតុការណ៍ពេលល្ងាច

គណបក្សប្រជាជន និងគណបក្សសង្គ្រោះជាតិ បានចេញសេចក្តីថ្លែងការណ៍ថា "ជំនួបកំពូល" នឹងកើតមាន "ដើម្បីដោះស្រាយវិបត្តិនយោបាយរបស់កម្ពុជា"។[៩] ជំនួបកំពូលនឹងត្រូវប្រព្រឹត្តទៅនៅថ្ងៃទី២២ ខែកក្កដា វេលាម៉ោង ៩ ព្រឹក នៅវិមាន ព្រឹទ្ធសភា។

យោងតាមសម្តីរបស់ឯកឧត្តម សម រង្ស៊ី ចំនុចសំខាន់នៃជំនួបកំពូលនោះគឺ ការបង្កើតគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោតថ្មី ដែលស្ថិតក្រោមរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា រួមទាំងការបោះឆ្នោត

---

[៨] May, T., “CNRP Lawmaker Summonsed,” Phnom Penh Post, July 21 2014, http://www.phnompenhpost.com/national/cnrp-lawmaker-summonsed

[៩] Ponnudurai, P., “Cambodian Parties Agree to Hold Talks to End „Deepening‟ Political Crisis‟, Radio Free Asia, July 20 2014, http://www.rfa.org/english/news/cambodia/talks-07202014220938.html

ឃុំសង្កាត់ និងបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ ដែលគណបក្សសង្គ្រោះជាតិ បានឯកភាពឲ្យរៀបចំជាបន្តបន្ទាប់នៅខែកុម្ភៈ ឆ្នាំ២០១៧ និង២០១៨។[១០]

**<u>ថ្ងៃទី២១ ខែកក្កដា ឆ្នាំ២០១៤: ហេតុការណ៍ពេលព្រឹក</u>**

ពាក្យចចាមអារ៉ាមដែលថា មន្ត្រីគណបក្សសង្គ្រោះជាតិទាំង ៨ រូប នឹងត្រូវបានដោះលែងឲ្យនៅក្រៅឃុំ កាន់តែស៊ីចង្វាក់គ្នាជាមួយការព្រួយបារម្ភរបស់អ្នកឃ្លាំមើលឯករាជ្យមួយចំនួនដែលថា មន្ត្រីដែលជាប់ឃុំឃាំង ត្រូវបានប្រើប្រាស់ជាថ្នូរក្នុងការចរចា។

**<u>ថ្ងៃទី២១ ខែកក្កដា ឆ្នាំ២០១៤: ហេតុការណ៍ពេលល្ងាច</u>**

អ្នកស្រាវជ្រាវពន្ធនាគាររបស់អង្គការលីកាដូ នៅតែត្រូវបានរារាំងមិនឲ្យចូលពន្ធនាគារព្រៃស។ នៅមណ្ឌលអប់រំកែប្រែទី២ មន្ត្រីគណបក្សសង្គ្រោះជាតិពីររូបបានជួបលោកស្រី មូរ សុខហួរ ប៉ុន្តែនៅតែមិនអាចចូលជួបតំណាងរាស្ត្រជាប់ឆ្នោតគណបក្សសង្គ្រោះជាតិផ្សេងទៀត ដែលនៅមណ្ឌលអប់រំកែប្រែទី១នោះទេ។

បើទោះបីជាមានការស្នើសុំជាច្រើនលើក ស្ថានទូតអាមេរិកត្រូវបានបដិសេធនូវសិទ្ធិចូលសួរសុខទុក្ខលោកស្រី មូរ សុខហួរ ដែលមានសញ្ជាតិអាមេរិក។[១១]

**<u>ថ្ងៃទី២២ ខែកក្កដា ឆ្នាំ២០១៤: ហេតុការណ៍ពេលព្រឹក</u>**

ជំនួបកំពូលរវាងមន្ត្រីគណបក្សប្រជាជនកម្ពុជា និងគណបក្សសង្គ្រោះជាតិ ប្រព្រឹត្តទៅនៅវិមាន ព្រឹទ្ធសភា។ ប្រធានបទសំខាន់ៗ នៃការចរចារ គឺជុំវិញកំណែទម្រង់ប្រព័ន្ធបោះឆ្នោត កាលបរិច្ឆេទការបោះឆ្នោត និងកំណែទម្រង់ទៅលើប្រព័ន្ធផ្សព្វផ្សាយ និងស្ថានប័នរដ្ឋសភា។[១២]

ស្របពេលការចរចាកំពុងតែប្រព្រឹត្តទៅ ចៅក្រមស៊ើបសួរ លោក កែវ មុនី បានទៅជួបមន្ត្រីគណបក្សសង្គ្រោះជាតិដែលកំពុងជាប់ឃុំឃាំងនៅពន្ធនាគារព្រៃស ដើម្បីសួរព័ត៌មានបន្ថែម។ ទោះជាយ៉ាងណាខណៈកំពុងរង់ចាំព័ត៌មានបន្ថែមពីតុលាការទាក់ទងអ្វីនឹងកើតឡើង ចំពោះមន្ត្រីដែលជាប់ឃុំឃាំងនោះ

---

[១០] Meas, S., & Ponniah, K., "CPP, CNRP „Final Talks" on Tuesday", Phnom Penh Post, July 21 2014 http://www.phnompenhpost.com/national/cpp-cnrp-final-talks-tuesday

[១១] Cuddy, A., "Sochua 'Off Limits to Embassy'", Phnom Penh Post, July 22 2014, http://www.phnompenhpost.com/national/sochua-%E2%80%98-limits-us-embassy%E2%80%99

[១២] Meas, S. & Ponniah, K., "Hopes High for Resolution", The Phnom Penh Post, July 22 2014, http://www.phnompenhpost.com/national/hopes-high-resolution

លោក កែវ មុនី បានបញ្ឈប់ការសម្ភាសន៍ភ្លាមៗ នៅម៉ោងប្រហែល ១១ ព្រឹក បន្ទាប់ពីសម្ភាស៍បានត្រឹមតែមន្ត្រី ៣ រូប ក្នុងចំណោមមន្ត្រីដែលជាប់ឃុំឃាំងចំនួន ៨ រូប។

**ថ្ងៃទី២២ ខែកក្កដា ឆ្នាំ២០១៤៖ ហេតុការណ៍ពេលល្ងាច**

ក្នុងសេចក្តីថ្លែងការណ៍រួម មន្ត្រីគណបក្សប្រជាជនកម្ពុជា និងគណបក្សសង្គ្រោះជាតិ បានប្រកាសថា គណបក្សទាំងពីរបានឈានដល់ការព្រមព្រៀងគ្នា។ ចំណុចដែលបានព្រមព្រៀងមានដូចជា៖

- គណបក្សសង្គ្រោះជាតិនឹងទទួលយកអាសនៈ ក្នុងរដ្ឋសភា ទាំង ៥៥ របស់ខ្លួន។
- តំណាងរាស្ត្រ ២ រូប របស់គណបក្សប្រជាជនកម្ពុជា នឹងទទួលតំណែងជាប្រធាន និងអនុប្រធានទី២ នៃរដ្ឋសភា ខណៈតំណាងរាស្ត្រគណបក្សសង្គ្រោះជាតិ ១ រូប នឹងទទួលតំណែងជាអនុប្រធានទី១ នៃរដ្ឋសភា។
- គណបក្សទាំងពីរអះអាងថា នឹងធ្វើការជាមួយគ្នា ដើម្បីដោះស្រាយបញ្ហាដែលមិនបានបញ្ជាក់ច្បាស់លាស់មួយចំនួន ដោយឈរលើគោលការណ៍ប្រជាធិបតេយ្យ និង នីតិរដ្ឋ។
- គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោតថ្មី ដែលនឹងត្រូវប្រែក្លាយជាស្ថាប័នធម្មនុញ្ញ នឹងមានសមាជិក ៩ រូប៖ ៤ រូបមកពីគណបក្សប្រជាជនកម្ពុជា ៤ រូបមកពីគណបក្សសង្គ្រោះជាតិ និង ១ រូប ទៀត ស្ថិតក្រោមការយល់ព្រមពីគណបក្សទាំងពីរ។
- គណបក្សទាំងពីរបានឯកភាពគ្នាកំណត់លើកាលបរិច្ឆេទបោះឆ្នោតលើកក្រោយ ប៉ុន្តែមិនត្រូវបានបញ្ជាក់ច្បាស់លាស់។
- គណបក្សទាំងពីរបានឯកភាពគ្នាលើការបែងចែកអំណាចរវាងអំណាចនីតិបញ្ញត្តិ និងអំណាចនីតិប្រតិបត្តិ ឲ្យកាន់តែច្បាស់លាស់ជាមុនថែមទៀត ប៉ុន្តែមិនបាន បញ្ជាក់អំពីវិធានការបែបណានោះទេ។
- បង្កើតគណៈកម្មាធិការនៃរដ្ឋសភាថ្មីមួយទៀត គឺគណៈកម្មការប្រឆាំងអំពើពុករលួយ។
- គណបក្សទាំងពីរនឹងដឹកនាំគណៈកម្មាធិការ ៥ ម្នាក់ ក្នុងចំណោមគណៈកម្មាធិការ ទាំង ១០ នៃរដ្ឋសភា។
- ថ្នាក់ដឹកនាំនៃព្រឹទ្ធសភានឹងធ្វើការរៀបចំឡើងវិញ
- ស្ថាប័នជាតិមួយចំនួននឹងត្រូវពង្រឹង ដើម្បីធានានូវឯករាជ្យភាព និងគិតគូរអំពីផលប្រយោជន៍របស់ជាតិ។[១៣]

[១៣] គណបក្សសង្គ្រោះជាតិ, *កិច្ចព្រមព្រៀង ស្តីពីដំណោះស្រាយនយោបាយរវាងគណបក្សប្រជាជនកម្ពុជា និងគណបក្សសង្គ្រោះជាតិ*, គណបក្សសង្គ្រោះជាតិ, ថ្ងៃទី២២ ខែកក្កដា ឆ្នាំ២០១៤, http://www.nationalrescueparty.org/cnrp-cpp-joint-agreement-22-07-2014/

បន្ទាប់ពីបញ្ចប់នៃការចរចារនេះ មន្ត្រីគណបក្សសង្គ្រោះជាតិទាំង ៨ រូប ត្រូវបានដោះលែងពីមណ្ឌលអប់រំកែប្រែទី ១ និងទី២ នៅវេលាម៉ោង ៩:៤៥ ល្ងាច ដោយមានវត្តមានអ្នកគាំទ្រជាង ៣៥០ នាក់។ ទោះជាយ៉ាងណា បទចោទមិនត្រូវបានទំលាក់ចោលនោះទេ។

**ថ្ងៃទី២៣ ខែកក្កដា ឆ្នាំ២០១៤៖ព្រឹត្តិការណ៍ពេលថ្ងៃរសៀល**

អ្នកនាំពាក្យគណបក្សសង្គ្រោះជាតិ លោក យឹម សុវណ្ណ ប្រកាសថាមន្ត្រីជាន់ខ្ពស់បីនាក់នៃគណបក្សសង្គ្រោះជាតិ ឯកឧត្តម សម រង្ស៊ី ឯកឧត្តម កឹម សុខា និងឯកឧត្តម ប៉ុល ហំ នឹងចូលក្រាបបង្គំគាល់ព្រះមហាក្សត្រនៅព្រះបរមរាជវាំងនៅថ្ងៃទី២៤ ខែកក្កដា ឆ្នាំ២០១៤ នៅម៉ោង ៤រសៀល។ គណបក្សទាំងពីរដែលដឹកនាំដោយឯកឧត្តម សម រង្ស៊ី និងសម្តេចនាយករដ្ឋមន្ត្រី ហ៊ុន សែន នឹងក្រាបទូលនូវលទ្ធផលនៃការចរចាថ្វាយព្រះករុណា ព្រះបាទនរោត្តម សីហមុនី។

**ថ្ងៃទី២៤ ខែកក្កដា ឆ្នាំ២០១៤៖ ព្រឹត្តិការណ៍ពេលព្រឹក**

គណបក្សសង្គ្រោះជាតិប្រកាសថា ឯកឧត្តម សម រង្ស៊ី នឹងក្លាយជាសមាជិកសភាមណ្ឌលខេត្តកំពង់ចាម ជំនួសឯកឧត្តម គួយ ប៊ុនរឿន ដែលត្រូវក្លាយជាសមាជិកម្នាក់នៃសមាជិកគណកម្មាធិការជាតិរៀបចំការបោះឆ្នោតដែលជ្រើសរើសដោយគណបក្សសង្គ្រោះជាតិ។

**ថ្ងៃទី២៤ ខែកក្កដា ឆ្នាំ២០១៤៖ ព្រឹត្តិការណ៍ពេលរសៀល**

សម្តេចនាយករដ្ឋមន្ត្រី ហ៊ុន សែន និងឯកឧត្តម សម រង្ស៊ី ចូលក្រាបទូលព្រះករុណា ព្រះបាទនរោត្តម សីហមុនី នៅព្រះបរមរាជវាំង ហើយទូលថ្វាយព្រះករុណាអំពីកិច្ចព្រមព្រៀងនយោបាយរវាងគណបក្សប្រជាជនកម្ពុជា និងគណបក្សសង្គ្រោះជាតិកាលពីថ្ងៃទី២២ ខែកក្កដា ឆ្នាំ២០១៤។

**ថ្ងៃទី២៥ ខែកក្កដា ឆ្នាំ២០១៤៖ ព្រឹត្តិការណ៍ពេលព្រឹក**

ឯកឧត្តម កឹម សុខា ចូលខ្លួនឆ្លើយបំភ្លឺនៅសាលាដំបូងរាជធានីភ្នំពេញ ប៉ុន្តែបានចេញមកវិញបន្ទាប់ពីកន្លះម៉ោងក្រោយមក។

សាលារាជធានីភ្នំពេញ អនុញ្ញាតឲ្យគណបក្សសង្គ្រោះជាតិប្រារព្ធសន្និបាតសមាជិកក្រុមប្រឹក្សាថ្នាក់ជាតិរបស់ខ្លួននៅមុខវត្តបទុមវតី នៅថ្ងៃទី២៧ ខែកក្កដា ឆ្នាំ២០១៤។

**ថ្ងៃទី២៥ ខែកក្កដា ឆ្នាំ២០១៤៖ ព្រឹត្តិការណ៍ពេលរសៀល**

គណបក្សសង្គ្រោះជាតិ ប្រារព្ធសន្និបាតថ្នាក់ជាតិរបស់ខ្លួននៅមុខវត្តបទុមវតី ដោយមានសមាជិកនិងអ្នកគាំទ្រចំនួន ៥០០០ នាក់ ចូលរួម។ សន្និបាតបានឈានដល់ការព្រមព្រៀងចំនួន ៧ ចំនុច៖

- គាំទ្រការតស៊ូមតិផ្នែកនយោបាយដោយឈរលើគោលការណ៍អហិង្សា
- គាំទ្រគោលនយោបាយលើកិច្ចព្រមព្រៀងលើដំណោះស្រាយនយោបាយរវាងគណបក្សសង្គ្រោះជាតិ និងគណបក្សប្រជាជនកម្ពុជា
- គាំទ្ររូបមន្ត ៤+៤+១ នៃសមាជិកគណកម្មាធិការជាតិរៀបចំការបោះឆ្នោត និងជ្រើសរើសសមាជិកទីប្រាំបួននៃគណកម្មាធិការជាតិមុនពេលចូលប្រជុំក្នុងរដ្ឋសភា
- គាំទ្រកំណែទម្រង់រដ្ឋសភា
- តំណាងរាស្ត្រគណបក្សសង្គ្រោះជាតិត្រូវកសាងសមត្ថភាពរបស់អ្នកទាំងនោះនៅក្នុងការទាមទារឲ្យមានកំណែទម្រង់ស្ថាប័នជាតិ
- ជំរុញឲ្យគណបក្សប្រជាជនកម្ពុជាអនុវត្តចំនុចទាំងប្រាំពីរនៃគោលនយោបាយរបស់គណបក្សសង្គ្រោះជាតិ
- ការពារយុត្តិធម៌សង្គម បូរណភាពទឹកដី និងផលប្រយោជន៍ប្រជាពលរដ្ឋកម្ពុជា

## ថ្ងៃទី២៨ ខែកក្កដា ឆ្នាំ២០១៤៖ ព្រឹត្តិការណ៍ពេលរសៀល

តំណាងរាស្ត្រមណ្ឌលព្រៃវែងគណបក្សប្រជាជនកម្ពុជា លោក ឈាង វុន អះអាងថា ឯកឧត្តម សម រង្ស៊ី នឹងក្លាយជាប្រធានគណកម្មាការប្រឆាំងអំពើពុករលួយនៅក្នុងរដ្ឋសភា។ ឯកឧត្តម កឹម សុខា នឹងទទួលតំណែងជាអនុប្រធានទីមួយ ហើយតំណាងរាស្ត្រគណបក្សប្រជាជនកម្ពុជាមណ្ឌលកំពង់ធំ ឯកឧត្តម ងួន ញ៉ិល នឹងក្លាយជាអនុប្រធានទីពីរនៃរដ្ឋសភា។

លោកស្រីវេជ្ជបណ្ឌិត ពុង ឈីវកេក ទទួលយកសំណើរជាបេក្ខជនទីប្រាំបួននៃសមាជិកគណកម្មាធិការជាតិរៀបចំការបោះឆ្នោតថ្មី នៅក្នុងលក្ខខណ្ឌដែលគណកម្មាធិការនេះឯករាជ្យក្នុងការជ្រើសរើសបុគ្គលិក និងដំណើរការដោយស្វ័យភាព ហើយអាចទទួលយកជំនួយពីម្ចាស់ជំនួយអន្តរជាតិ។

## ថ្ងៃទី៣០ ខែកក្កដា ឆ្នាំ២០១៤៖ ព្រឹត្តិការណ៍ពេលព្រឹក

នៅក្នុងលិខិតជូនឯកឧត្តម ស ខេង ឯកឧត្តម សម រង្ស៊ី បានសរសេរថា តំណាងរាស្ត្រជាប់ឆ្នោតគណបក្សសង្គ្រោះជាតិទាំង ៥៥ នាក់ នឹងចូលប្រជុំក្នុងរដ្ឋសភា។ ប៉ុន្តែ នៅក្នុងលិខិតមានសរសេរលក្ខខណ្ឌជាច្រើន ដែលរួមទាំងឯករាជ្យភាព និងអភ័យឯកសិទ្ធិនៃសមាជិកទាំងអស់នៃគណកម្មាធិការជាតិរៀបចំការបោះឆ្នោត បន្ថែមលើការធ្វើវិសោធនកម្មមាត្រា ៧៦ នៃរដ្ឋធម្មនុញ្ញ និងការបង្កើតជំពូកថ្មី ពាក់ព័ន្ធនឹងច្បាប់ស្តីពីការបោះឆ្នោត។[១៤]

[១៤] មាត្រា ៧៦, ១៥១, ១៥២, ១៥៣

<u>**ថ្ងៃទី១ ខែសីហា ឆ្នាំ២០១៤៖ ព្រឹត្តិការណ៍ពេលព្រឹក**</u>

ឯកឧត្តម ស ខេង ឆ្លើយតបនឹងលិខិតរបស់ឯកឧត្តម សម រង្ស៊ីកាលពីថ្ងៃទី៣០ ដោយដកចេញនូវការនិយាយអំពីអភ័យឯកសិទ្ធិពាក់ព័ន្ធនឹងសមាជិកគណកម្មាធិការជាតិរៀបចំការបោះឆ្នោត។ នេះត្រូវបានគេប្រកាសថាពីរក្រុម មួយមកពីគណបក្សសង្គ្រោះជាតិ ហើយមួយទៀតមកពីគណបក្សប្រជាជនកម្ពុជា នឹងជួបគ្នានៅម៉ោង ៣រសៀល ដើម្បីពិភាក្សាពីការធ្វើវិសោធនកម្មរដ្ឋធម្មនុញ្ញ។

<u>**ថ្ងៃទី១ ខែសីហា ឆ្នាំ២០១៤៖ ព្រឹត្តិការណ៍ពេលរសៀល**</u>

ឯកឧត្តម កឹម សុខា និងមន្ត្រីគណបក្សសង្គ្រោះជាតិ ៨នាក់ ដែលត្រូវបានចាប់ខ្លួនពាក់ព័ន្ធនឹងអំពើហិង្សានៅទីលានប្រជាធិបតេយ្យកាលពីថ្ងៃទី១៥ ខែកក្កដា ត្រូវបានតុលាការកោះហៅឲ្យចូលខ្លួននៅសាលាដំបូងរាជធានីភ្នំពេញរវាងពីថ្ងៃទី៨ ដល់ថ្ងៃទី១៣ ខែសីហា។

<u>**ថ្ងៃទី២ ខែសីហា ឆ្នាំ២០១៤៖ ព្រឹត្តិការណ៍ពេលព្រឹក**</u>

នៅម៉ោង ៧ និង៣០ នាទី លោក ឃឹម ជំរឿន ជាប្រធានយុវជនគណបក្សសង្គ្រោះជាតិរាជធានីភ្នំពេញ ត្រូវបានចាប់ខ្លួននៅភោជនីយ៍ដ្ឋាននៅទីក្រុងតាខ្មៅ ភាគខាងត្បូងរាជធានីភ្នំពេញ។ លោក ជំរឿន ត្រូវបានបញ្ជូនទៅកាន់ស្នងការដ្ឋានរាជធានីភ្នំពេញ ហើយត្រូវបានចោទប្រកាន់ជាផ្លូវការដូចមន្ត្រីគណបក្សសង្គ្រោះជាតិទាំង ៨ ផ្សេងទៀត ដែលត្រូវបានឃុំខ្លួនអស់មួយសប្តាហ៍នៅពន្ធនាគារ ម១ និង ម២ លើករណីអំពើហិង្សានៅទីលានប្រជាធិបតេយ្យកាលពីថ្ងៃទី១៥ ខែកក្កដា។

<u>**ថ្ងៃទី០២ ខែសីហា ឆ្នាំ២០១៤៖ ព្រឹត្តិការណ៍ពេលរសៀល**</u>

លោក ឃិន ជំរឿន ត្រូវបានបញ្ជូនទៅកាន់មណ្ឌលអប់រំកែប្រែទី១ នៅវេលាម៉ោង ១២ និង ១០នាទី រសៀល។ នៅពេលជាមួយគ្នានេះដែរ នគរបាលបានចាប់ខ្លួនតំណាងយុវជនគណបក្សសង្គ្រោះជាតិ ២នាក់បន្ថែមទៀតនៅរាជធានីភ្នំពេញគឺ លោក សាន គឹមហេង ប្រធានយុវជនខណ្ឌទួលគោក និងលោក នាង សុឃុន ប្រធានយុវជនខណ្ឌច្បារអំពៅ។

ជំរឿន មានឈ្មោះនៅក្នុងឯកសាររបស់តុលាការដែលរៀបចំឡើងដោយព្រះរាជអាជ្ញាកាន់សំណុំរឿង លោក កែវ សុជាតិ កាលពីថ្ងៃទី១៦ ខែកក្កដា ហើយគាត់ត្រូវបានចោទប្រកាន់ជាផ្លូវការជាមួយមន្ត្រីគណបក្សសង្គ្រោះជាតិចំនួន ៨នាក់ផ្សេងទៀតពីបទ ញុះញង់ ផ្តួចផ្តើមគំនិតប្រើប្រាស់អំពើហិង្សា និងដឹកនាំ

ចលនាកុបកម្ម។ លោក គឹម ហេង និង សុឃុន ត្រូវបានចោទប្រកាន់ពីបទប្រើប្រាស់អំពើហិង្សា បង្កឧបសគ្គដល់មន្ត្រីរាជការ និងចូលរួមក្នុងចលនាកុបកម្ម។[១៥]

## ថ្ងៃទី០៤ ខែសីហា ឆ្នាំ២០១៤៖ ព្រឹត្តិការណ៍ពេលព្រឹក

នាយករដ្ឋមន្ត្រី ហ៊ុន សែន បានថ្លែងសុន្ទរកថាក្នុងពិធីបញ្ចប់ការសិក្សារបស់សិស្ស/និស្សិតនៅសកលវិទ្យាល័យ Western នៅទីក្រុងរណបកោះពេជ្រ ក្នុងរាជធានីភ្នំពេញ ដោយបានព្រមាន "អ្នកដែលញុះញង់ និងប្រព្រឹត្តអំពើហិង្សានឹងត្រូវប្រឈមមុខជាមួយច្បាប់ជាធរមាន"។[១៦]

## ថ្ងៃទី០៤ ខែសីហា ឆ្នាំ២០១៤៖ ព្រឹត្តិការណ៍ពេលរសៀល

សមាជិកគ្រួសាររបស់មេដឹកនាំយុវជនគណបក្សសង្គ្រោះជាតិទាំង ៣នាក់ មិនត្រូវបានអនុញ្ញាតឲ្យចូលក្នុងពន្ធនាគារ ម១ នៅពេលដែលអ្នកទាំងនោះព្យាយាមចូលទៅសួរសុខទុកអ្នកមេដឹកនាំយុវជនទាំងនោះ។ អ្នកទាំងនោះត្រូវបានគេប្រាប់ថាមិនត្រូវបានអនុញ្ញាតឲ្យចូលទៅសួរសុខទុកនោះទេ រហូតដល់អ្នកទាំងនោះមានការអនុញ្ញាតពីតុលាការ ឬអគ្គនាយកដ្ឋានពន្ធនាគារ (GDP)។ កាលពីលើកមុន នៅថ្ងៃទី៣ ខែសីហា សមាជិកគ្រួសារអ្នកទាំងនោះធ្លាប់បានព្យាយាមចូលទៅសួរសុខទុករួចមកហើយ។

## ថ្ងៃទី០៥ ខែសីហា ឆ្នាំ២០១៤៖ ព្រឹត្តិការណ៍ពេលរសៀល

មេធាវីរបស់មេដឹកនាំយុវជនគណបក្សសង្គ្រោះជាតិ បានដាក់សំណើដើម្បីស្នើសុំឲ្យក្រុមគ្រួសារបានចូលទៅសួរសុខទុក ទៅកាន់ លោក កែវ មុន្នី ចៅក្រមស៊ើបសួរ។ សំណើនេះមិនត្រូវបានគេឆ្លើយតបអស់រយៈពេល ១៧ថ្ងៃ។

ព្រះបាទនរោត្តម សីហមុនី បានយាងចូលរួមក្នុងពិធីស្បថចូលកាន់តំណែងក្នុងរដ្ឋសភារបស់សមាជិកសភា គណបក្សសង្គ្រោះជាតិទាំង ៥៥នាក់នៅវេលាម៉ោង ៤រសៀល។

## ថ្ងៃទី០៦ ខែសីហា ឆ្នាំ២០១៤៖ ព្រឹត្តិការណ៍ពេលព្រឹក

ទីលានប្រជាធិបតេយ្យត្រូវបានបើកជាសាធារណៈឡើងវិញ ក្រោយពីសមាជិកសភារបស់គណបក្សសង្គ្រោះជាតិទាំង ៥៥នាក់ បានចូលស្បថកាន់តំណែង។

---

[១៥] ជំរឿន ត្រូវបានចោទប្រកាន់យោងតាមមាត្រា ២៨, ២១៨, ៤៥៩ និង ៤៩៥។ លោក គឹមហេង និងសុឃុន ត្រូវបានចោទប្រកាន់តាមមាត្រា ២១៨, ៤៥៦, ៤៥៧ និង៥០៤

[១៦] May, T., "„Acts of Violence‟ Won‟t be Tolerated," Phnom Penh Post, August 6 2014, http://www.phnompenhpost.com/national/%E2%80%98acts-violence%E2%80%99-won%E2%80%99t-be-tolerated-premier

**<u>ថ្ងៃទី០៧ ខែសីហា ឆ្នាំ២០១៤៖ ព្រឹត្តិការណ៍ពេលព្រឹក</u>**

ចៅក្រមស៊ើបអង្កេត លោក កែវ មុន្នី បដិសេធសំណើស្នើសុំដោះលែងឲ្យនៅក្រៅឃុំបណ្ដោះអាសន្ន រង់ចាំសវនាការ ពាក់ព័ន្ធនឹងមេដឹកនាំយុវជនទាំងបីនាក់របស់គណបក្សសង្គ្រោះជាតិដែលបានជាប់ឃុំនៅ ម១ ក្នុងពន្ធនាគារព្រៃសរ។

**<u>ថ្ងៃទី០៧ ខែសីហា ឆ្នាំ២០១៤៖ ព្រឹត្តិការណ៍ពេលរសៀល</u>**

នាយករដ្ឋមន្ត្រី ហ៊ុន សែន បានព្រមានដល់គណបក្សសង្គ្រោះជាតិថាការដោះស្រាយផ្នែកនយោបាយអាចនឹងបរាជ័យ ប្រសិនបើគណបក្សសង្គ្រោះជាតិមិនបានចូលរួមក្នុងកិច្ចប្រជុំពេញអង្គលើកទី១ របស់រដ្ឋសភានៅថ្ងៃទី៨ ខែសីហា។

**<u>ថ្ងៃទី០៨ ខែសីហា ឆ្នាំ២០១៤៖ ព្រឹត្តិការណ៍ពេលព្រឹក</u>**

រដ្ឋសភាជាតិបើកកិច្ចប្រជុំពេញអង្គលើកទី១ របស់ខ្លួន ដោយមានវត្តមានទាំងអស់នៃសមាជិកសភាគណបក្សសង្គ្រោះជាតិ និងគណបក្សប្រជាជន។

**<u>ថ្ងៃទី០៩ ខែសីហា ឆ្នាំ២០១៤៖ ព្រឹត្តិការណ៍ពេលព្រឹក</u>**

មួយសប្ដាហ៍បន្ទាប់ពីមានការចាប់ខ្លួនអ្នកទាំងនោះ ឯកឧត្តម សម រង្ស៊ី និងសមាជិកសភាគណបក្សសង្គ្រោះជាតិបានទៅសួរសុខទុកតំណាងយុវជនគណបក្សសង្គ្រោះជាតិទាំង ៣នាក់ ដែលបានឃុំខ្លួននៅ ម១។ ប៉ុន្តែក្រុមគ្រួសាររបស់អ្នកជាប់ឃុំទាំងនោះនូវតែត្រូវបានគេបដិសេធសិទ្ធិក្នុងការចូលសួរសុខទុក្ខ។

**<u>ថ្ងៃទី១១ ខែសីហា ឆ្នាំ២០១៤៖ ព្រឹត្តិការណ៍ពេលព្រឹក</u>**

សមាជិកសភាគណបក្សសង្គ្រោះជាតិទាំង ៧នាក់ ដែលជាប់ឃុំពាក់ព័ន្ធនឹងករណីអំពើហិង្សានៅទីលានប្រជាធិបតេយ្យកាលពីថ្ងៃទី១៥ ប្រកាសថាអ្នកទាំងនោះនឹងមិនចូលខ្លួនតាមរយៈដីកាកោះរបស់សាលាដំបូងរាជធានីភ្នំពេញសម្រាប់សំណួរបន្ថែមទៀតនៅសប្ដាហ៍នេះទេ ដោយសារអ្នកទាំងនោះមានអភ័យឯកសិទ្ធិជាសមាជិកសភា។

**<u>ថ្ងៃទី១១ ខែសីហា ឆ្នាំ២០១៤៖ ព្រឹត្តិការណ៍ពេលរសៀល</u>**

ចៅក្រមស៊ើបសួរ លោក កែវ មុន្នី លើកឡើងថាលោកនឹងមិនបន្តសួរសំណួរទៅកាន់សមាជិកសភាគណបក្សសង្គ្រោះជាតិទាំង ៧នាក់ (៦នាក់បានឃុំខ្លួននៅ ម១ និង ម២ អំឡុងពេលពីថ្ងៃទី១៥ ដល់ថ្ងៃទី២២ ខែកក្កដា និងឯកឧត្តម កឹម សុខា) ពាក់ព័ន្ធនឹងអំពើហិង្សាដែលបានកើតឡើងនៅទីលានប្រជាធិបតេយ្យ

ប៉ុន្តែលោកនឹងបន្តសួរសំណួរទៅកាន់មន្ត្រីគណបក្សសង្គ្រោះជាតិ លោក អឿន ណារិទ្ធ នៅថ្ងៃទី១៣ ខែសីហា វេលាម៉ោង ២រសៀល។

**<u>ថ្ងៃទី១៣ ខែសីហា ឆ្នាំ២០១៤៖ ព្រឹត្តិការណ៍ពេលរសៀល</u>**

តុលាការខេត្តកំពង់ឆ្នាំង កោះហៅមន្ត្រីគណបក្សសង្គ្រោះជាតិចំនួន ៣នាក់ ឲ្យចូលខ្លួនបំភ្លឺនៅថ្ងៃទី១៥ ខែសីហា ឆ្នាំ២០១៤។

សាលាដំបូងរាជធានីភ្នំពេញ ប្រកាសថាខ្លួនបានកោះហៅសមាជិកគណបក្សសង្គ្រោះជាតិនៅខេត្តបន្ទាយមានជ័យ លោក មាជ សុវណ្ណារ៉ា បន្ថែមជាមួយនឹងសមាជិកយុវជនគណបក្សលោក សាន សីហៈ (បងប្អូនលោក សាន គីមហេង ដែលត្រូវបានចាប់ខ្លួនកាលពីថ្ងៃទី២ ខែសីហា) និងលោក ទេព ណារិន។

ទាំង សីហាក់ និង ណារិន នឹងត្រូវបានធ្វើការសាកសួរដោយសាលាដំបូងរាជធានីភ្នំពេញនៅថ្ងៃទី២៧ ខែសីហា ខណៈណាពេលដែល មាជ សុវណ្ណារ៉ា នឹងត្រូវចូលខ្លួនបំភ្លឺនៅក្នុងសវនាការនៅថ្ងៃទី០១ ខែកញ្ញា។ ជាមួយគ្នានេះដែរ តំណាងយុវជនគណបក្សសង្គ្រោះជាតិទាំង ៣នាក់ (ជំរឿន គីមហេង និងសុឃុន) ដែលត្រូវបានគេចាប់ខ្លួននៅថ្ងៃទី០២ ខែសីហា ហើយបច្ចុប្បន្នត្រូវបានឃុំខ្លួននៅពន្ធនាគារ ម១ នឹងចូលខ្លួនមកតុលាការនៅមុខអង្គស៊ើបអង្កេតរបស់សាលាឧទ្ធរណ៍រាជធានីភ្នំពេញ ដែលសវនាការនោះធ្វើឡើងជាអសាធារណៈពាក់ព័ន្ធនឹងសំណើសុំឲ្យនៅក្រៅឃុំរង់ចាំសវនាការនៅថ្ងៃទី២២ ខែសីហា វេលាម៉ោង៨ព្រឹក។

**<u>ថ្ងៃទី១៥ ខែសីហា ឆ្នាំ២០១៤៖ ព្រឹត្តិការណ៍ពេលរសៀល</u>**

ចៅក្រមស៊ើបសួរ លោក កែវ មុន្នី ចេញដីកាកោះហៅ សុវណ្ណារ៉ា សីហាក់ និង ណារិន ឲ្យចូលខ្លួនមកបំភ្លឺដើម្បីធ្វើការសាកសួរនៅសាលាដំបូងរាជធានីភ្នំពេញពាក់ព័ន្ធករណីអំពើហិង្សានៅទីលានប្រជាធិបតេយ្យកាលពីថ្ងៃទី១៥ ខែកក្កដា។

លើសពីនេះទៅទៀត តុលាការចេញដីកាកោះថ្មីមួយទៅកាន់សកម្មជននៅមូលដ្ឋាន និងជាអ្នកគាំទ្រគណបក្សសង្គ្រោះជាតិ លោក អ៊ុក ពេជ្រសំណាង។ សំណាង នឹងចូលខ្លួននៅមុនសវនាការសាលាដំបូងរាជធានីភ្នំពេញនៅថ្ងៃទី២៦ ខែសីហា វេលាម៉ោង ២រសៀល។

សមាជិកយុវជនគណបក្សសង្គ្រោះជាតិ សាន សីហាក់ និង ទេព ណារិន នឹងចូលខ្លួនមុនសវនាការសាលាដំបូងរាជធានីភ្នំពេញនៅព្រឹកថ្ងៃទី២៧ ខែសីហា ខណៈពេលដែល មាជ សុវណ្ណារ៉ា នឹងចូលខ្លួនក្នុងតុលាការនៅថ្ងៃទី១ ខែកញ្ញា វេលាម៉ោង ២រសៀល។

ជាសរុប មន្ត្រី និងអ្នកគាំទ្រគណបក្សសង្គ្រោះជាតិចំនួន ៨នាក់ នឹងត្រូវប្រឈមមុខនឹងនីតិវិធីផ្លូវច្បាប់ពាក់ព័ន្ធនឹងករណីអំពើហិង្សានៅទីលានប្រជាធិបតេយ្យ អ្នកទាំងនោះរួមមាន៖ លោក អឿន ណារិទ្ធ,

ឃិន ជំរឿន, សាន គីមហេង, នាង សុឃុន, មៀច សុវណ្ណារ៉ា, សាន សីហៈ, ទេព ណារិន និងលោក អ៊ុក ពេជ្រសំណាង។

អង្គការលើកលែងទោសអន្តរជាតិ ចេញនូវសេចក្តីថ្លែងការណ៍មួយអំពាវនាវស្នើសុំចាត់វិធានការតាមផ្លូវច្បាប់មុនពេលដែលមន្ត្រីគណបក្សសង្គ្រោះជាតិ "ត្រូវបានបំបិទមាត់ដោយហេតុផលនយោបាយ និងដោយតាមអំពើចិត្ត ដែលជាការរំលោភសិទ្ធិសេរីភាពក្នុងការបញ្ចេញមតិ សេរីភាពក្នុងការជួបជុំដោយអហិង្សា និងសេរីភាពពីការឃុំខ្លួនដោយមិនស្របច្បាប់"។[១៧]

## ថ្ងៃទី១៩ ខែសីហា ឆ្នាំ២០១៤៖ ព្រឹត្តិការណ៍ពេលព្រឹក

ក្រោយពីមានការអនុញ្ញាតពីអគ្គនាយកដ្ឋានពន្ធនាគារ (GDP) សមាជិកសភាគណបក្សសង្គ្រោះជាតិត្រូវបានអនុញ្ញាតឲ្យចូលទៅសួរសុខទុកតំណាងយុវជនគណបក្សសង្គ្រោះជាតិដែលបានឃុំខ្លួននៅពន្ធនាគារ ម១។

## ថ្ងៃទី២១ ខែសីហា ឆ្នាំ២០១៤៖ ព្រឹត្តិការណ៍ពេលព្រឹក

មន្ត្រីជាន់ខ្ពស់រដ្ឋសភាម្នាក់ ប្រកាសថាការបោះឆ្នោតជ្រើសរើសប្រធាន និងអនុប្រធានរដ្ឋសភានឹងត្រូវធ្វើឡើងនៅសប្តាហ៍ក្រោយ។ ហើយក៏មានការរាប់ទាំងការបោះឆ្នោតជ្រើសរើសគណៈកម្មការទាំង ១០ ដែលនឹងត្រូវធ្វើឡើងនៅថ្ងៃទី២៦ ខែសីហា ឆ្នាំ២០១៤។

## ថ្ងៃទី២១ ខែសីហា ឆ្នាំ២០១៤៖ ព្រឹត្តិការណ៍ពេលរសៀល

ឯកឧត្តម ហ្សូរ វ៉ាន់ បញ្ជាក់ថា អ្នកគាំទ្រ និងជាសកម្មជនគណបក្សសង្គ្រោះជាតិ លោក អ៊ុក ពេជ្រសំណាង នឹងចូលខ្លួនក្នុងសាលាដំបូងរាជធានីភ្នំពេញនៅថ្ងៃទី២៦ ខែសីហា វេលាម៉ោង២រសៀល។ បន្ថែមលើសពីនេះទៅទៀត មានដីកាកោះហៅថ្មីមួយទៅកាន់សមាជិកយុវជនគណបក្សសង្គ្រោះជាតិ លោក អាន បាថាម ឲ្យចូលខ្លួនក្នុងតុលាការនៅថ្ងៃជាមួយគ្នានឹង សំណាង ដែរ។

មេធាវីអង្គការ លីកាដូ ជួបជាមួយមន្ត្រីតុលាការដើម្បីតាមដានលិខិតស្នើសុំឲ្យក្រុមគ្រួសារមានសិទ្ធិចូលសួរសុខទុកតំណាងយុវជនទាំង ៣នាក់ក្នុងពន្ធនាគារ ម១។ មេធាវី ជួបជាមួយចៅក្រមស៊ើបសួរ លោក កែវ មុន្នី ដែលនិយាយថាមន្ត្រីតុលាការមិនមានសិទ្ធិអនុញ្ញាតឲ្យក្រុមគ្រួសារចូលទៅសួរសុខទុក្ខនោះឡើយ។ ប៉ុន្តែគាត់បានផ្តល់យោបល់ថា ក្រុមគ្រួសាររបស់អ្នកដឹកនាំយុវជនគណបក្សសង្គ្រោះជាតិគួរតែដាក់

---

[១៧] Amnesty International, "Urgent Action: Opposition Party Members Arrested, Charged," Amnesty International, August 15 2014, http://www.amnesty.org/en/library/asset/ASA23/006/2014/en/6dbbba76-6d83-42a9-977a-28ac26add6d3/asa230062014en.pdf

លិខិតទៅកាន់ក្រសួងមហាផ្ទៃ។ មុន្នី និយាយថាគាត់អាចសម្រេចលើលិខិតដែលធ្វើឡើងដោយមនុស្សជាក់លាក់ ដែលមកពីស្ថាប័ន រដ្ឋាភិបាលដូចជា ព្រឹទ្ធសភា សមាជិកសភា ឬមន្ត្រីរាជរដ្ឋាភិបាល។

**<u>ថ្ងៃទី២២ ខែសីហា ឆ្នាំ២០១៤៖ ព្រឹត្តិការណ៍ពេលព្រឹក</u>**

វេលាម៉ោង ៩ និង ៣០នាទីព្រឹក អ្នកដឹកនាំយុវជនគណបក្សសង្គ្រោះជាតិទាំង ៣នាក់ ដែលត្រូវបានចាប់ខ្លួន និងឃុំខ្លួនក្នុងពន្ធនាគារ ម១ កាលពីថ្ងៃទី២ ខែសីហា ត្រូវបានដោះលែងឲ្យនៅក្រៅឃុំបណ្តោះអាសន្នរង់ចាំសវនាការដោយការដាក់ប្រាក់តម្កល់ចំនួន ១០០០ដុល្លាអាមេរិក។ លោក ឃិន ជំរឿន សាន គឹមហេង និង នាង សុឃុន ត្រូវបានដោះលែងបណ្តោះអាសន្នស្ថិតនៅក្រោមការត្រួតពិនិត្យរបស់តុលាការ។

**<u>ថ្ងៃទី២២ ខែសីហា ឆ្នាំ២០១៤៖ ព្រឹត្តិការណ៍ពេលរសៀល</u>**

ម៉ោងប្រហែល ៦ល្ងាច មេដឹកនាំយុវជនគណបក្សសង្គ្រោះជាតិទាំង ៣នាក់ ត្រូវបានដោះលែងពីពន្ធនាគារ ម១។

**<u>ថ្ងៃទី២៦ ខែសីហា ឆ្នាំ២០១៤៖ ព្រឹត្តិការណ៍ពេលព្រឹក</u>**

ការបោះឆ្នោតជ្រើសរើសតំណែងប្រធាន និងអនុប្រធាននៅរដ្ឋសភា ចាប់ផ្តើម។ ឯឧត្តម ងួន ញិល សមាជិកសភាគណបក្សប្រជាជនក្លាយជាអនុប្រធានទី២ ដោយសម្លេង១២២ នៃសមាជិកសភាទាំងអស់ ខណ:ពេលដែល ឯកឧត្តម កឹម សុខា ក្លាយជាអនុប្រធានទី១ រដ្ឋសភាដោយសម្លេង ១១៦ នៃសមាជិកសភា។

**<u>ថ្ងៃទី២៦ ខែសីហា ឆ្នាំ២០១៤៖ ព្រឹត្តិការណ៍ពេលរសៀល</u>**

លោក អ៊ុក ពេជ្រសំណាង ចូលខ្លួននៅក្នុងសាលាដំបូងរាជធានីភ្នំពេញសម្រាប់ការសាកសួរជាមួយចៅក្រមស៊ើបសួរ លោក កែវ មុន្នី ។

ឯកឧត្តម អេង ឆៃអ៊ាង សមាជិកសភាគណបក្សសង្គ្រោះជាតិ ត្រូវបានគេបោះឆ្នោតឲ្យធ្វើជាប្រធានគណ:កម្មការសិទ្ធិមនុស្ស ហើយប្រធានគណកម្មាធិកាគណបក្សសង្គ្រោះជាតិ ឯកឧត្តម ប៉ុល ហំម ត្រូវបានបោះឆ្នោតធ្វើជាប្រធានគណ:កម្មការវិនិយោគ ផែនការ និងកសិកម្ម។

ឯកឧត្តម សុន ឆ័យ ប្រធានទទួលបន្ទុកបទវិន័យនៃគណបក្សសង្គ្រោះជាតិ ត្រូវបានបោះឆ្នោតជ្រើសតាំងធ្វើជាអនុប្រធានគណ:កម្មការសេដ្ឋកិច្ច ហិរញ្ញវត្ថុ ធនាគារ និងសវនកម្ម ស្ថិតនៅក្រោមសមាជិកសភាគណបក្សប្រជាជន ឯកឧត្តម ជាម យៀប។

**<u>ថ្ងៃទី២៧ ខែសីហា ឆ្នាំ២០១៤៖ ព្រឹត្តិការណ៍ពេលព្រឹក</u>**

ជាការភ្ញាក់ផ្អើល អ្នកស្រី មូ សុខហួរ បានធ្លាក់ការបោះឆ្នោតធ្វើជាប្រធានគណៈកម្មការសុខាភិបាល សង្គមកិច្ច អតីតយុទ្ធជន យុវនីតិសម្បទា កាងារបណ្តុះបណ្តាលវិជ្ជាជីវៈ និងកិច្ចការនារី ដោយទទួលបានសម្លេងត្រឹមតែ ៥៦តែប៉ុណ្ណោះ (សមាជិកសភាគណបក្សសង្គ្រោះជាតិទាំងអស់បូកនឹងសម្លេងមួយពីគណបក្សប្រជាជន)។

នៅក្នុងហេតុការណ៍ដដែល លោក យឹម សុវណ្ណ ធ្លាក់ក្នុងការបោះឆ្នោតធ្វើជាប្រធានគណៈកម្មការប្រឆាំងអំពើពុករលួយដែលទើបនឹងបង្កើតថ្មី។

**<u>ថ្ងៃទី២៧ ខែសីហា ឆ្នាំ២០១៤៖ ព្រឹត្តិការណ៍ពេលរសៀល</u>**

លោក សាន សីហាក់ ចូលខ្លួនបំភ្លឺនៅសាលាដំបូងរាជធានីភ្នំពេញសម្រាប់ការសាកសួរជាមួយចៅក្រមស៊ើបសួរ លោក កែវ មុន្នី ។

គណបក្សសង្គ្រោះជាតិសម្រេចចិត្តមិនជំទាស់ទៅនឹងការសម្រេចរបស់រដ្ឋសភាដោយការជំនួសអ្នកស្រី មូ សុខហួរ ដោយលោកជំទាវ កែ សុវណ្ណរតន៍ ជំនួសលោក យឹម សុវណ្ណ ដោយឯកឧត្តម ហូរ វ៉ាន់។ សុវណ្ណរតន៍ ត្រូវបានបោះឆ្នោតធ្វើជាប្រធានគណៈកម្មការសុខាភិបាល សង្គមកិច្ច អតីតយុទ្ធជន យុវនីតិសម្បទា កាងារបណ្តុះបណ្តាលវិជ្ជាជីវៈ និងកិច្ចការនារី ខណៈពេលដែលឯកឧត្តម ហូរ វ៉ាន់ ត្រូវបានបោះឆ្នោតធ្វើជាប្រធានគណៈកម្មការអង្កេត បោសសំអាត និងប្រឆាំងអំពើពុករលួយ។

ឯកឧត្តម យ៉ែម ប៉ុញ្ញឫទ្ធិ អ្នកនាំពាក្យគណបក្សសង្គ្រោះជាតិត្រូវបានបោះឆ្នោតធ្វើជាប្រធានគណៈកម្មការអប់រំ យុវជន កីឡា ធម្មការ កិច្ចការសាសនា វប្បធម៌ និងទេសចរណ៍។

តំណាងរាស្ត្រគណបក្សសង្គ្រោះជាតិ ឯកឧត្តម ឡុង រី ត្រូវបានបោះឆ្នោតធ្វើជាអនុប្រធានគណៈកម្មការមហាផ្ទៃ ការពារជាតិ និងមុខងារសាធារណៈ នៅក្រោម ឯកឧត្តម ហ៊ុន ណេង តំណាងរាស្ត្របក្សប្រជាជនកម្ពុជា ជាប្អូនប្រុសរបស់នាយករដ្ឋមន្ត្រី ហ៊ុន សែន ដែលជាប្រធាន។

ឯកឧត្តម ម៉ៅ មុនីវណ្ណ សមាជិកសភាគណបក្សសង្គ្រោះជាតិត្រូវបានបោះឆ្នោតធ្វើជាអនុប្រធានគណៈកម្មការ កិច្ចការសាធារណការ ដឹកជញ្ជូន ទូរគមនាគមន៍ ប្រៃសណីយ៍ ឧស្សាហកម្មរ៉ែ ថាមពល ពាណិជកម្ម រៀបចំដែនដី នគរូបនីយកម្ម និងសំណង់ ក្រោមលោកជំទាវ និន សាផុន សមាជិកសភាគណបក្សប្រជាជនកម្ពុជា។

លោកជំទាវ ជូឡុង សូមូរ៉ា សមាជិកសភាគណបក្សសង្គ្រោះជាតិត្រូវបានបោះឆ្នោតធ្វើជា អនុប្រធាន គណៈកម្មការកិច្ចការបរទេស សហប្រតិបត្តិការ អន្តរជាតិ ឃោសនាការ និងព័ត៌មាន ក្រោម ឯកឧត្តម ឈាង វុន សមាជិកសភាគណបក្សប្រជាជនកម្ពុជា។

ឯកឧត្តម អ៊ូ ច័ន្ទឫទ្ធិ ត្រូវបានបោះឆ្នោតធ្វើជាអនុប្រធានគណៈកម្មការនីតិកម្ម និងយុត្តិធម៌ ក្រោមឯកឧត្តមបណ្ឌិត ប៉ែន បញ្ញា សមាជិកសភាគណបក្សប្រជាជនកម្ពុជា។

**<u>ថ្ងៃទី២៩ ខែកញ្ញា ឆ្នាំ២០១៤៖ ព្រឹត្តិការណ៍ពេលព្រឹក</u>**

សមាជិកក្រុមប្រឹក្សាខណ្ឌច្បារអំពៅជាប់ឆ្នោតមកពីគណបក្សសង្គ្រោះជាតិ លោក ស៊ុំ ពុទ្ធី ត្រូវបានចាប់ខ្លួន ពាក់ព័ន្ធនឹងអំពើហិង្សា ដែលបានកើតឡើងនៅទីលានប្រជាធិបតេយ្យកាលពីថ្ងៃទី១៥ ខែកក្កដា។

លោក ពុទ្ធី ត្រូវបានចោទប្រកាន់ពីបទហិង្សាដោយចេតនាដោយមានស្ថានទម្ងន់ទោស (មាត្រា ២១៨ នៃក្រមព្រហ្មទណ្ឌ) ចូលរួមក្នុងចលនាកុបកម្ម (មាត្រា ៤៥៦ និង៤៥៧ នៃក្រមព្រហ្មទណ្ឌ) និងរារាំងមន្ត្រីរាជការសាធារណៈដោយមានស្ថានទម្ងន់ទោស (មាត្រា ៥០៤ នៃក្រមព្រហ្មទណ្ឌ)។ លោក ត្រូវបានបញ្ជូនខ្លួនទៅពន្ធនាគារ ម១ នៅព្រៃសរ ដើម្បីឃុំខ្លួនបណ្តោះអាសន្នរង់ចាំសវនាការ ដែលនេះធ្វើឲ្យលោកក្លាយជាមន្ត្រីគណបក្សសង្គ្រោះជាតិទី ១២ ដែលត្រូវបានចាប់ខ្លួនពាក់ព័ន្ធនឹងហិង្សានៅទីលានប្រជាធិបតេយ្យ។

លោក នឹងត្រូវប្រឈមមុខនឹងការជាប់ពន្ធនាគារចំនួន ១៥ឆ្នាំ និងពិន័យជាប្រាក់ចំនួន ៣.០០០ ដុល្លារអាមេរិក។

**<u>ថ្ងៃទី២៤ ខែតុលា ឆ្នាំ២០១៤៖ ព្រឹត្តិការណ៍ពេលព្រឹក</u>**

លោក អ៊ុក ពេជ្យសំណាង ដែលជាសកម្មជនមូលដ្ឋានដ៏ល្បីរបស់គណបក្សសង្គ្រោះជាតិ ត្រូវបានចាប់ខ្លួន ៤ថ្ងៃ បន្ទាប់ពីលោក ត្រូវបានគេវាយដំយ៉ាងធ្ងន់ធ្ងរ នៅពេលដែលកំពុងចូលរួមក្នុងការតវ៉ារបស់ជនរងគ្រោះដីធ្លីមកពីខេត្តព្រះវិហារ នៅក្បែរគេហដ្ឋានរបស់សម្តេចនាយករដ្ឋមន្ត្រី កាលពីថ្ងៃទី២០ ខែតុលា ឆ្នាំ ២០១៤។

សំណាង ត្រូវបានចោទប្រកាន់ពីបទល្មើសដូចគ្នា ដែលត្រូវបានចោទលើលោក ស៊ុំ ពុទ្ធីខាងលើ ពាក់ព័ន្ធនឹងហិង្សានៅទីលានប្រជាធិបតេយ្យ។

សំណាង ក៏ត្រូវបានចោទប្រកាន់ពាក់ព័ន្ធនឹងព្រឹត្តិការណ៍នៃការតវ៉ារបស់ពលរដ្ឋខេត្តព្រះវិហារ នៅថ្ងៃទី២០ ខែតុលា ផងដែរ ពីបទ ហិង្សាដោយចេតនាដោយមានស្ថានទម្ងន់ទោស (មាត្រា ២១៨ នៃក្រមព្រហ្មទណ្ឌ) បំផ្លាញទ្រព្យអ្នកដទៃដោយចេតនា និងមានស្ថានទម្ងន់ទោស (មាត្រា ៤១១ នៃក្រមព្រហ្មទណ្ឌ)

រារាំងមន្ត្រីរាជការសាធារណៈ (មាត្រា ៥០៣ នៃក្រមព្រហ្មទណ្ឌ) និងចូលរួមក្នុងសមាគមទុច្ចរិត (មាត្រា ៤៩៨ នៃក្រមព្រហ្មទណ្ឌ)។

សំណាង នឹងប្រឈមមុខនឹងការជាប់ពន្ធនាគារចំនួន ១០ ឆ្នាំ និងពិន័យជាប្រាក់ចំនួន ១០.៦២៥ ដុល្លារអាមេរិក។

**<u>ថ្ងៃទី១១ ខែវិច្ឆិកា ឆ្នាំ២០១៤៖ ព្រឹត្តិការណ៍ពេលព្រឹក</u>**

មន្ត្រីគណបក្សសង្គ្រោះជាតិនៅខេត្តបន្ទាយមានជ័យ លោក មាជ សុវណ្ណារ៉ា ត្រូវបានចាប់ខ្លួនដោយអាជ្ញាធររដ្ឋ នៅរាជធានីភ្នំពេញ និងឃុំខ្លួននៅប៉ុស្តិ៍នគរបាលព្រហ្មទណ្ឌកម្រិតធ្ងន់រាជធានីភ្នំពេញ។

ពីមុន សុវណ្ណារ៉ា ត្រូវបានកោះហៅចូលខ្លួនឆ្លើយបំភ្លឺដោយចៅក្រមស៊ើបសួរ លោក កែវ មុនី នៅសាលាដំបូងរាជធានីភ្នំពេញ កាលពីថ្ងៃទី១ ខែកញ្ញា ពាក់ព័ន្ធនឹងហិង្សានៅទីលានប្រជាធិបតេយ្យ។ ប៉ុន្តែដោយសារលោក ស្ថិតនៅក្រៅប្រទេសនៅពេលនោះ លោក មិនអាចមកចូលក្នុងតុលាការបានទេ។

លោក ត្រូវបានចោទប្រកាន់ពីបទញុះញង់ឲ្យមានហិង្សាដោយចេតនា (មាត្រា ២៨ និង២១៨ នៃក្រមព្រហ្មទណ្ឌ) ញុះញង់ឲ្យប្រព្រឹត្តបទឧក្រិដ្ឋ (មាត្រា ៤៩៥ នៃក្រមព្រហ្មទណ្ឌ) និងដឹកនាំចលនាកុបកម្ម (មាត្រា ៤៥៩ នៃក្រមព្រហ្មទណ្ឌ)។ លោក នឹងប្រឈមមុខនឹងការជាប់ពន្ធនាគារចំនួន ៣០ ឆ្នាំ និងពិន័យជាប្រាក់ ៣.៥០០ ដុល្លារអាមេរិក។

លោក កែ ឃឹម អ្នកបើកបរម៉ូតូ និងជាអ្នកគាំទ្រគណបក្សសង្គ្រោះជាតិ ដែលបានដឹកទង់ជាតិនៅថ្ងៃដែលមានហិង្សានៅទីលានប្រជាធិបតេយ្យ ត្រូវបានចាប់ខ្លួន និងឃុំខ្លួននៅពន្ធនាគារ ម១ នៅព្រៃសរ។

**<u>ថ្ងៃទី១៣ ខែវិច្ឆិកា ឆ្នាំ២០១៤៖ ព្រឹត្តិការណ៍ពេលព្រឹក</u>**

សមាជិកយុវជនគណបក្សសង្គ្រោះជាតិលោក ទេព ណារិន ត្រូវបានចាប់ខ្លួនដោយអាជ្ញាធររដ្ឋ បន្ទាប់ពីខកខានក្នុងការចូលរាយការណ៍នៅប៉ុស្តិ៍នគរបាលក្នុងតំបន់។ ណារិន ត្រូវបានបង្គាប់ឲ្យបង្ហាញខ្លួននៅមុខនគរបាល ជារៀងរាល់ពីរសប្តាហ៍ម្តង តាមដីកាបង្គាប់ឲ្យត្រួតពិនិត្យតាមផ្លូវតុលាការ។

ណារិន ត្រូវបានចោទប្រកាន់ដោយព្រះរាជអាជ្ញាកាន់សំណុំរឿង លោក កែវ សុជាតិ ពីការចូលរួមក្នុងហិង្សាដែលបានកើតឡើងនៅទីលានប្រជាធិបតេយ្យកាលពីថ្ងៃទី១៥ ខែកក្កដា ឆ្នាំ២០១៤។

បច្ចុប្បន្ន មន្ត្រី និងសកម្មជនគណបក្សសង្គ្រោះជាតិចំនួន ៨នាក់ ដែលត្រូវបានជាប់ឃុំនៅពន្ធនាគារ ម១ នៃព្រៃសរ មាន៖ លោក អ៊ុក ពេជ្យសំណាង លោក ស៊ុំ ពុទ្ធី សមាជិកក្រុមប្រឹក្សាខណ្ឌជាប់ឆ្នោតគណ

បក្សសង្គ្រោះជាតិ លោក មាជ សុវណ្ណារ៉ា មន្ត្រីគណបក្សសង្គ្រោះជាតិ និងសមាជិកយុវជនគណបក្ស លោក ទេព ណារិន។

ជាសរុប មន្ត្រី និងសកម្មជនគណបក្សសង្គ្រោះជាតិចំនួន ១៥ នាក់ ធ្លាប់ និងត្រូវបានចាប់ខ្លួន ពាក់ព័ន្ធនឹងអំពើហិង្សានៅទីលានប្រជាធិបតេយ្យកាលពីថ្ងៃទី១៥ ខែកក្កដា។

- លោកស្រី មូរ សុខហួរ — តំណាងរាស្ត្រមណ្ឌលបាត់ដំបង — ចាប់ខ្លួន ថ្ងៃទី១៥ ខែកក្កដា
- លោក ម៉ែន សុថាវរិន្ទ្រ — តំណាងរាស្ត្រមណ្ឌលកំពង់ធំ — ចាប់ខ្លួន ថ្ងៃទី១៥ ខែកក្កដា
- លោក កែវ ភិរម្យ — តំណាងរាស្ត្រមណ្ឌលក្រចេះ — ចាប់ខ្លួន ថ្ងៃទី១៥ ខែកក្កដា
- លោក ហូរ វ៉ាន់ — តំណាងរាស្ត្រមណ្ឌលភ្នំពេញ — ចាប់ខ្លួន ថ្ងៃទី១៥ ខែកក្កដា
- លោក រៀល ខេមរិន្ទ — តំណាងរាស្ត្រមណ្ឌលស្វាយរៀង — ចាប់ខ្លួន ថ្ងៃទី១៦ ខែកក្កដា
- លោក អឿន ណារិទ្ធិ — មន្ត្រីផ្នែកកិច្ចការសាធារណៈ — ចាប់ខ្លួន ថ្ងៃទី១៦ ខែកក្កដា
- លោក ឡុង រី — តំណាារាស្ត្រមណ្ឌលបន្ទាយមានជ័យ — ចាប់ខ្លួន ថ្ងៃទី១៧ ខែកក្កដា
- លោក នុត រំដួល — តំណាងរាស្ត្រមណ្ឌលកំពង់ស្ពឺ — ចាប់ខ្លួន ថ្ងៃទី១៧ ខែកក្កដា
- លោក ឃីន ជំរឿន — ប្រធានយុវជនសាខាភ្នំពេញ — ចាប់ខ្លួន ថ្ងៃទី២ ខែសីហា
- លោក សាន គីមហេង — អ្នកដឹកនាំយុវជនសាខាខណ្ឌទួលគោក — ចាប់ខ្លួន ថ្ងៃទី២ ខែសីហា
- លោក នាង សុឃុន — អ្នកដឹកនាំយុវជនសាខាខណ្ឌច្បារអំពៅ — ចាប់ខ្លួន ថ្ងៃទី២ ខែសីហា
- លោក ស៊ុំ ពុទ្ធី — សមាជិកក្រុមប្រឹក្សាខណ្ឌច្បារអំពៅ — ចាប់ខ្លួន ថ្ងៃទី ២៩ ខែកញ្ញា
- លោក អ៊ុក ពេជ្យសំណាង — អ្នកគាំទ្រ និងសកម្មជនគណបក្ស — ចាប់ខ្លួន ថ្ងៃទី២៤ ខែតុលា
- លោក មាជ សុវណ្ណារ៉ា — បេក្ខជនគណបក្សខេត្តបន្ទាយមានជ័យ — ចាប់ខ្លួន ថ្ងៃទី១១ ខែកញ្ញា
- លោក កែ ឃីម — អ្នកគាំទ្រគណបក្សសង្គ្រោះជាតិ — ចាប់ខ្លួន ថ្ងៃទី១១ ខែកញ្ញា
- លោក ទេព ណារិន — សមាជិកយុវជនគណបក្ស — ចាប់ខ្លួន ថ្ងៃទី១៣ ខែកញ្ញា

ការចាប់ខ្លួនទាំងនេះ បានកើតឡើងនៅពេលដែលក្រុមការងារគណបក្សសង្គ្រោះជាតិ និងគណបក្សប្រជាជនកម្ពុជា កំពុងព្រាងច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅនៃគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ដែលបានជាប់គាំងលើចំនុចមួយចំនួន។

នាយករងកិច្ចការសាធារណៈគណបក្សសង្គ្រោះជាតិ អ្នកនាង កឹម មនោវិទ្យា ប្រាប់កាសែត The Cambodia Daily ថា "គណបក្សប្រជាជនកម្ពុជា កំពុងប្រើប្រាស់ល្បិចនៃការចាប់ខ្លួនមន្ត្រីគណបក្សសង្គ្រោះជាតិ ដើម្បីដាក់សំពាធលើគណបក្ស នៅពេលដែលគណបក្សរបស់យើងមិនយល់ព្រមលើចំនុចមួយចំនួននៅក្នុងការបង្កើតគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត"។

**ថ្ងៃទី២៨ ខែវិច្ឆិកា ឆ្នាំ២០១៤៖ ព្រឹត្តិការណ៍ពេលព្រឹក**

សម្តេចនាយករដ្ឋមន្ត្រី ហ៊ុន សែន និងប្រធានគណបក្សសង្គ្រោះជាតិ ឯកឧត្តម សម រង្ស៊ី បានជួបប្រជុំឯកជន នៅវិមានរដ្ឋសភា ដោយបានចេញនូវលទ្ធផលមួយ គឺកិច្ចព្រមព្រៀងដែលបានចុះហត្ថលេខា ដោយអះអាងថាបញ្ហាទាំងអស់ជុំវិញការព្រាងច្បាប់ស្តីពីគណកម្មាធិការជាតិរៀបចំការបោះឆ្នោតថ្មី ត្រូវបានដោះស្រាយ។ ជាពិសេស ហើយទោះបីជាមានការតស៊ូពីគណបក្សសង្គ្រោះជាតិ ក៏ឯកឧត្តម សម រង្ស៊ី បានយល់ព្រមតាមការទាមទាររបស់គណបក្សប្រជាជនកម្ពុជា ដោយតម្រូវឲ្យសមាជិកគណកម្មាការមានសញ្ជាតិខ្មែរតែមួយ។

កិច្ចព្រមព្រៀងនេះ ក៏បាននិយាយអំពីការផ្តល់ អង់តាណា ដល់ស្ថានីយ៍វិទ្យុរបស់គណបក្សសង្គ្រោះជាតិ ក៏ដូចជាសិទ្ធិបើកស្ថានីយ៍ទូរទស្សន៍ដល់ក្រុមហ៊ុនគាំទ្រគណបក្សនេះផងដែរ។

**ថ្ងៃទី២៨ ខែវិច្ឆិកា ឆ្នាំ២០១៤៖ ព្រឹត្តិការណ៍ពេលរសៀល**

ចៅក្រមស៊ើបសួរ លោក កែវ មុនី បានបំបែកករណីលើតំណាងរាស្ត្រគណបក្សសង្គ្រោះជាតិទាំង ៧ នាក់ ចេញពីករណីថ្មី ទៅលើមន្ត្រី និងអ្នកគាំទ្រគណបក្សសង្គ្រោះជាតិទាំង ១១ នាក់ ដែលនឹងត្រូវបើសវនាការនៅថ្ងៃទី២៥ ខែធ្នូ ឆ្នាំ២០១៤។

លោក អឿន ណារិទ្ធិ, យីន ជំរឿន, សាន គីមហេង, នាង សុឃុន, សាន សីហៈ, អន បាថាម, អ៊ុក ពេជ្យ សំណាង, កៃ ឃីម, ស៊ុំ ពុទ្ធី, មាជ សុវណ្ណារ៉ា និងលោក ទេព ណារិន ត្រូវបានកោះហៅឲ្យឆ្លើយបំភ្លឺលើបទចោទដែលពាក់ព័ន្ធនឹងអំពើហិង្សាកើតឡើងនៅទីលានប្រជាធិបតេយ្យកាលពីថ្ងៃទី១៥ ខែកក្កដា ឆ្នាំ ២០១៤។

លោក ណារិទ្ធិ, ជំរឿន និងលោក សុវណ្ណារ៉ា ត្រូវបានចោទប្រកាន់ពីបទដឹកនាំចលនាកុបកម្ម (មាត្រា ៤៥៩ នៃក្រមព្រហ្មទណ្ឌ)។ អ្នកដទៃ នឹងចូលខ្លួនក្នុងសវនាការពីបទចោទ ចូលរួមក្នុងចលនាកុបកម្ម (មាត្រា ៤៥៦ និង៤៥៧ នៃក្រមព្រហ្មទណ្ឌ)។ ប្រសិនបើត្រូវបានផ្តន្ទាទោសពីបទល្មើសចូលរួមក្នុងចលនាកុបកម្ម នោះនឹងត្រូវទទួលទោសពន្ធនាគារពី ៧ ទៅ ១៥ឆ្នាំ ហើយពីបទល្មើសដឹកនាំចលនាកុបកម្ម នោះនឹងត្រូវទទួលទោសពន្ធនាគារពី ២០ ទៅ ៣០ឆ្នាំ។

ករណីលើតំណាងរាស្ត្រទាំង ៧នាក់ (លោកស្រី មួរ សុខហួរ, លោក ម៉ែន សុថាវរិន្ទ្រ, លោក កែវ ភិរម្យ, លោក ហូរ វ៉ាន់, លោក រៀល ខេមរិន្ទ្រ, លោក ឡុង រី និងលោក នុត រំដួល) នៅតែស្ថិតក្នុងការស៊ើបសួរ ដោយចៅក្រមស៊ើបសួរ លោក កែវ មុនី។ ករណី នឹងបន្តដាក់ជនល្មើស "មិនត្រូវបានដឹង"។

អាជ្ញាយុកាលនៃបទឧក្រិដ្ឋនៅក្នុងប្រទេសកម្ពុជា គឺ ២០ ឆ្នាំ។